ទាំងឡាយ ទាំងព្រះនិព្វាន ទាំងបដិបទា រមែងប្រៀបផ្ទៀបស្មើគ្នា បាន ដូច្នោះដែរ ។ យើងពិចារណារកមើលនូវសាស្តា ជាអ្នកបញ្ញត្តនូវបដិបទាជាទីទៅកាន់ព្រះនិព្វានយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ ព្រះមានព្រះភាគ ទ្រង់បានពួកសេក្ខបុគ្គល ដែលបឋមទៅកាន់បដិបទា ហើយនឹងព្រះខីណាស្រព ដែលមានព្រហ្មចរិយធម៌អប់រំស្រេចហើយជាគ្នីគ្នា តែព្រះមានព្រះភាគ ទ្រង់មិនជាប់ព្រះទ័យនឹងគ្នីគ្នានោះទេ ទ្រង់ប្រកបសេចក្តីត្រេកអរ តែមួយអង្គឯង ។ យើងពិចារណារកមើលនូវសាស្តា ជាអ្នកប្រកបនូវសេចក្តីត្រេកអរតែម្នាក់ឯងយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមាន ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគ អង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ លាភសម្រេចហើយ សេចក្តីសរសើរក៏សម្រេចហើយ ដល់ព្រះមានព្រះភាគអង្គនោះ ទាំងពួកភ្ញៀវ ក៏មានសភាពជាអ្នកស្រឡាញ់រាប់រកព្រះអង្គ ព្រះមានព្រះភាគ អង្គនោះ ប្រាសចាកសេចក្តីស្រេកឃ្លានហើយ រមែងសោយ នូវអាហារ (តាមធម្មតា) ។

ឯវំ វិគតមទំ អាហារមាហារេយមានំ ឥមិនាបង្គេន សមន្នាគតំ សត្តាវំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន កថាតា ។ យថាភតិ ខោ បន សោ កថាភ តថាការី យថាការី តថាភតិ ឥតិ យថាភតិ តថាការី យថាការី តថាភតិ ។ ឯវំ ឆម្មា-នុធម្មបដិបន្នំ ឥមិនាបង្គេន សមន្នាគតំ សត្តាវំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន កថាតា ។ តិណ្ណាវិចិកិច្ឆោ ខោ បន សោ កថាភ វិគតកថំកថោ បរយោសិតសង្កប្បោ អជ្ឈាសយំ អាធិព្រហ្មចរិយំ ។ ឯវំ តិណ្ណាវិចិកិច្ឆំ វិគតកថំ-កថំ បរិយោសិតសង្កប្បំ អជ្ឈាសយំ អាធិព្រហ្មចរិយំ ឥមិនាបង្គេន សមន្នាគតំ សត្តាវំ នេវ អតីតំសេ

យើងពិចារណារកមើលនូវសាស្តា ជាអ្នកប្រាសចាកសេចក្តីស្រើនឹង ហើយ
បរិភោគនូវអាហារយ៉ាងនេះ ដែលប្រកបដោយគុណនេះ តាំងចំណែក
កាល ដែលកន្លងទៅហើយ មិនឃើញមានទេ តាំងកាលឥឡូវនេះ ក្រៅ
អំពីព្រះមានព្រះភាគ អង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ ព្រះ
មានព្រះភាគអង្គនោះ ទ្រង់ត្រាស់យ៉ាងណា ទ្រង់ធ្វើយ៉ាងនោះ ទ្រង់
ធ្វើយ៉ាងណា ទ្រង់ត្រាស់យ៉ាងនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាង
ណា ទ្រង់ធ្វើយ៉ាងនោះ ទ្រង់ធ្វើយ៉ាងណា ទ្រង់ត្រាស់យ៉ាងនោះ ដោយ
ប្រការយ៉ាងនេះ ។ យើងពិចារណារកមើលនូវសាស្តា ជាអ្នកប្រតិបត្តិ
នូវធម៌ដ៏សមគួរដល់ធម៌យ៉ាងនេះ ដែលប្រកបដោយគុណនេះ តាំងចំណែក
កាលដែលកន្លងទៅហើយ មិនឃើញមានទេ តាំងកាលឥឡូវនេះ ក្រៅអំពី
ព្រះមានព្រះភាគ អង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ ព្រះមាន
ព្រះភាគអង្គនោះ ព្រះអង្គដូចជាផុតសេចក្តីសង្ស័យអស់ហើយ ព្រះអង្គប្រាស
ចាកសេចក្តីឆៀងឆ្ងល់អស់ហើយ ទ្រង់មានព្រះតម្រិះ ដល់ទីបំផុតហើយ
ដោយព្រហ្មចរិយធម៌ដ៏ដើម ជានិស្ស័យដ៏ខ្ពង់ខ្ពស់ ។ យើងពិចារណា
រកមើលនូវសាស្តា ជាអ្នកដូចជាផុតសេចក្តីសង្ស័យ ប្រាសចាកសេចក្តីឆៀង
ឆ្ងល់ មានតម្រិះដល់នូវទីបំផុត ដោយព្រហ្មចរិយធម៌ដ៏ដើម ជានិស្ស័យ
ដ៏ខ្ពង់ខ្ពស់យ៉ាងនេះ ដែលប្រកបដោយគុណនេះ តាំងចំណែកកាល ដែល

สมฺปชฺชสฺส น ปเนตาทิโส อญฺญตฺร เตน ภควตา-
ติ ฯ สเมฺม โข ภนฺเต สงฺฆสฺส เอกจฺเจ ปุคฺคลา ทุปฺปญฺญา
สงฺฆมาสฺส ภควตา อฏฺฐ ยถาภุจฺเจ วณฺเณ ปยิรุ-
ปาหาสิ ฯ

(๕๗) เตน สุทฺธ ภนฺเต ปฺรหฺมา สงฺฆมาเก
อตฺตมโน เหาติ ปมุทิโต ปีติสาเมนสฺสชาโต ภค
วาโต อฏฺฐ ยถาภุจฺเจ วณฺเณ สุตฺวา ฯ อถ ภนฺเต
ปฺรหฺมา สงฺฆมาเก ฉิทฺปาติกึ อตฺตภาวึ อภิสมฺปาเทตฺวา
ภควาวณฺเณ(๑) ปาตุ ปญฺจสิเข เอกมนฺต ติฏฺฐสิ
ตาคตสฺส ฯ สเข(๒) เยหาสึ อฏฺฐงฺคสมนฺนาคเต
อนฺตลิกฺเข ปลฺลงฺเกน นิสีทิ ฯ เสยฺยถาปิ ภนฺเต
พลวา ปุริโส สุปจฺจตฺถเต ก ปลฺลงฺเก สเข ก
ภูมิภาเค ปลฺลงฺเกน นิสีเทยฺย เอวเมว โข ภนฺเต
ปฺรหฺมา สงฺฆมาเก เยหาสึ อฏฺฐงฺคสมนฺนาคเต
อนฺตลิกฺเข ปลฺลงฺเกน นิสีทิตฺวา เอเว ตาคตสฺส
อาเมนฺเตสิ ตึ กึ ปญฺจสิเข ภาเยนฺโต เอก ตาคตสฺส

๑ ฉ. ม. กุมาวณฺเณ ฯ ๒ ฉ. สเขตน ทิสฺสติ ฯ

កន្ទង់ទៅហើយ មិនឃើញមានទេ តថាគតឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគរង្គីនោះចេញហើយ ក៏មិនឃើញមានឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន សក្កទេវរាជ ជាធំជាងពួកទេវតា ឃានសំដែងគុណជារបស់ពិតចំង ៨ ប្រការ របស់ព្រះមានព្រះភាគនេះឯង ដល់សនង្កុមារព្រហ្ម ។

(៥៧) បពិត្រព្រះអង្គដ៏ចំរើន ព្រោះហេតុនោះ ឃានជាសនង្កុមារ-ព្រហ្ម មានចិត្តត្រេកអរ រីករាយ កើតបំតិសោមនស្ស ព្រោះឃានស្តាប់គុណជារបស់ពិតចំង ៨ ប្រការ របស់ព្រះមានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចំរើន ត្រានោះ សនង្កុមារព្រហ្ម និម្មិតអត្តភាពដំណើសលុប ដូចជាកេទកុមារ មានផ្ទៃ ៥ ព្រាកដហើយ ដល់ពួកទេវតាជាន់តាវត្តិង្ស ។ ព្រហ្មនោះ ក៏ហោះឡើងទៅកាន់អាកាស អង្គុយពែនភ្នែនលើផ្ទៃអាកាសរលេង ។ បពិត្រព្រះអង្គដ៏ចំរើន បុរសមានកម្លាំង អង្គុយពែនភ្នែនលើបល្ល័ង្កដែលគេក្រាលល្អហើយ ឬលើភូមិភាគដ៏រាបស្មើ មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចំរើន សនង្កុមារព្រហ្ម ហោះឡើងទៅកាន់អាកាស អង្គុយពែនភ្នែនលើផ្ទៃអាកាស រលេង ក៏មានឧបមេយ្យដូច្នោះដែរ ហើយនិយាយនឹងពួកទេវតាជាន់តាវត្តិង្សថា នែអ្នកដ៏ចំរើនទាំងឡាយ ពួកទេវតាជាន់តាវត្តិង្សសំគាល់សេចក្តីនោះដូចម្តេច

យាវ នីយន្តំ បវត្តោ ញ(១) សោ ភគវា អ-
ហោសិ ។ ភូតបុព្ពំ ភោ ភវំ ឱសម្ពតិ(២) ជាម
អហោសិ ។ ឱសម្ពតិស្ស បញ្ញោ តោវិន្ទោ ជាម
ព្រាហ្មណោ បុរោហិតោ អហោសិ ឱសម្ពតិស្ស
រញ្ញោ វេណ្ហ ជាម ភរុមាកេ បុត្តោ អហោសិ ។
តោវិន្ទស្ស ព្រាហ្មណស្ស ជោតិជាលោ ជាម មា-
ណាវកេ បុត្តោ អហោសិ ។ ឥតិ វេណ្ហ ច ភរុបុត្តោ
ជោតិជាលោ ច មាណាវកេ អញ្ញេ ច ឆ ខត្តិយា
ឥច្ចេតេ អដ្ឋ សហាយា អហេសុំ ។ អថខោ ភោ(៣)
អហោរត្តានំ អច្ចយេន តោវិន្ទោ ព្រាហ្មណោ ភាល-
មភាសិ ។ តោវិន្ទេ ព្រាហ្មណេ ភាលភតេ ភវំ
ឱសម្ពតិ បរិទេវេសិ យស្មឹ វត ភោ មយំ សមយេ
តោវិន្ទេ ព្រាហ្មណេ សព្ពភិច្ចានិ សម្មភេសុដ្ឋិត្វា(៤)
បញ្ចហិ ភាមគុណេហិ សមប្បិតា សមង្គិភូតា បរិចា-
រេម តស្មឹ ខោ បន(៥) សមយេ តោវិន្ទោ ព្រាហ្មណោ
ភាលភតោតិ ។ ឯវំ វុត្តេ ភោ វេណ្ហ ភរុបុត្តោ

---

១ ឱ. ប ។ ២. ឱ. ឱសម្ពតិ ។ ៣ ឱ ភោតិ ន ទិស្សតិ ។ ៤ ម. សម្ភវេសុដ្ឋិត្វា ។
៥ ឱ. ខោ បនាតិ ន ទិស្សតិ ។

ព្រះមានព្រះភាគនោះ ជាបុគ្គលមានបញ្ញាច្រើន អស់កាលអង្វែងមក
ហើយ ។ ម្នាលអ្នកដ៏ចំរើន រឿងឆ្ងាប់មានមកហើយថា មានស្តេចមួយព្រះ
អង្គ ទ្រង់ព្រះនាមទិសម្បតិ ។ មានព្រាហ្មណ៍ឈ្មោះគោវិន្ទៈ ជាបុរោហិត
របស់ព្រះបាទទិសម្បតិ ។ ព្រះបាទទិសម្បតិ មានព្រះរាជបុត្រ ១ ព្រះ
អង្គ ទ្រង់ព្រះនាមរណុកុមារ ។ គោវិន្ទព្រាហ្មណ៍ មានកូនប្រុសម្នាក់
ឈ្មោះជោតិបាលមាណព ។ ជនទាំង ៨ នាក់នេះ គឺ រណុកជបុត្រ ១
ជោតិបាលមាណព ១ ទឹងក្សត្រ(១) ៦ ព្រះអង្គទៀត សុទ្ធតែជាសំឡាញ់
ទឹងគ្នា ។ ម្នាលអ្នកដ៏ចំរើន លុះថ្ងៃទឹងយប់ កន្លងទៅហើយ គោវិន្ទ-
ព្រាហ្មណ៍ ក៏ធ្វើមរណកាលទៅ ។ ម្នាលអ្នកដ៏ចំរើន កាលដែល
គោវិន្ទព្រាហ្មណ៍ ធ្វើមរណកាលទៅហើយ ព្រះបាទទិសម្បតិ ទ្រង់
ព្រះកន្សែងសោកស្តាយថា ឧហ៎ុ កុង៑សម័យណា យើងបានប្រគល់ភារ-
កិច្ចទាំងពួងដោយស្រួលបួល ដល់គោវិន្ទព្រាហ្មណ៍ហើយ កំពុងតែស្គប់
ស្គល់ មូលមិត ផ្គេកផ្គិតដោយកាមគុណទាំង ៥ សម័យនោះឯង
គោវិន្ទព្រាហ្មណ៍ ក៏ធ្វើមរណកាលទៅ ។ ម្នាលអ្នកដ៏ចំរើន កាលព្រះ
បាទទិសម្បតិ ទ្រង់ព្រះកន្សែងសោកស្តាយយ៉ាងនោះហើយ រណុកជបុត្ត

---

១ អដ្ឋកថាថា ស្តេច ៦ អង្គទៀតនោះ គឺ តត្តភូ ១ ព្រហ្មទត្ត ១ វេស្សភូ ១ ភារតៈ ១
ធតរដ្ឋ ១ ធតរដ្ឋមួយទៀត ១ ។

ភជាយំ ឯសម្បតី ឯតន្តរភេទ មា ខោ តុំ ឯវ តោ-
រិន្ទេ ព្រាហ្មណោ ភាលកតេ អតិពាឡ្ហំ បរិទេវេសិ អត្ថ
ឯវ តោរិន្ទស្ស ព្រាហ្មណស្ស ជោតិបាលោ ជាម មា-
ណាកេ បុត្តោ បណ្ឌិតតរោ ឯវ បិតរ អលមត្តទស-
តរោ ឯវ បិតរ យេបិ តស្ស[1] បិតា អត្ថេ អនុសាសិ
តេបិ ជោតិបាលស្សេវ មាណវស្ស អនុសាសនីយាតិ ។
ឯវំ ភុមាភតិ ។ ឯវំ ឯភតិ ។ អថខោ តោ ភជា
ឯសម្បតិ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ តុំ អម្ភោ
បុរិស យេន ជោតិបាលោ ជាម មាណាកេ តេនុ-
បសង្កម្ប ឧបសង្កមិត្វា ជោតិបាលំ មាណវំ ឯវំ
វទេហិ ភវមត្ត ភវន្តំ ជោតិបាលំ មាណវំ ភជា
ឯសម្បតិ ភវន្តំ ជោតិបាលំ មាណវំ អាមន្តយតិ
ភជា ឯសម្បតិ តោតោ ជោតិបាលស្ស មាណវស្ស
ឧស្សុជតាមោតិ ។ ឯវំ ឯភតិ ខោ[2] តោ សោ
បុរិសោ ឯសម្បតិស្ស បញ្ញ បដិស្សុត្វា យេន
ជោតិបាលោ មាណាកេ តេនុបសង្កមិ ឧបសង្កមិត្វា

---

๑ ឱ. ម. យេបស្ស ។ ๒ ឱ. ខោត ន ទិស្សតិ ។

ក៏ក្រាបបង្គំទូលព្រះបាទធសម្បតិ យ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំទ្រង់ព្រះកន្សែង នឹងគោរិន្ទព្រាហ្មណ៍ ដែលឆ្លើមរណកាលទៅនោះភ្លាំងពេកឡើយ បពិត្រព្រះសម្មតិទេព គោរិន្ទព្រាហ្មណ៍ មានកូនប្រុសម្នាក់ ឈ្មោះជោតិបាលមាណព ជាបណ្ឌិតវិសេសជាងបិតាផង ជាអ្នកមុះមុត អាចកាត់សេចក្តីបានជាងបិតាផង បិតារបស់ជោតិបាលមាណពនោះ ប្រៀនប្រដៅនូវសេចក្តីពាំងឡាយណា សេចក្តីពាំងឡាយនោះ សុទ្ធតែជាពាក្យប្រៀនប្រដៅ របស់ជោតិបាលមាណព ។ ព្រះបាទធសម្បតិ មានព្រះពាដនុង្ការថា ម្នាលកុមារ យ៉ាងហ្នឹងមែនឬ ។ ព្រះរណុញ្ជកុមារ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព យ៉ាងហ្នឹងមែន ។ ម្នាលអ្នកដ៏ចំរើន គ្រានោះ ព្រះបាទធសម្បតិ មានព្រះពាដនុង្ការឲ្យហៅបុរសម្នាក់ថា នែបុរសដ៏ចំរើន ឯងចូរមកនេះ ឯងចូរចូលទៅរកជោតិបាលមាណព លុះចូលទៅដល់ហើយ ចូរនិយាយទំនងជោតិបាលមាណពយ៉ាងនេះថា សូមសេចក្តីចំរើនមាន ដល់ជោតិបាលមាណពដ៏ចំរើនចុះ ព្រះបាទធសម្បតិ មានព្រះពាដនុង្ការ ឲ្យហៅជោតិបាលមាណពដ៏ចំរើន ព្រះបាទធសម្បតិ ចង់ជួបនឹងជោតិបាលមាណពដ៏ចំរើន ។ ម្នាលអ្នកដ៏ចំរើន ពាដកុមារនោះទទួលព្រះពាដនុង្ការព្រះបាទធសម្បតិថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ហើយចូលទៅរកជោតិបាលមាណព លុះចូល

ជោតិបាលំ នាណាវំ ឯតទវោច ភវមត្ថុ ភវន្តំ ជោតិបាលោ
មាណាវំ កថា និសម្បតិ ភវន្តំ ជោតិបាលំ មាណាវំ
អាមន្តយតិ កថា និសម្បតិ ភោតោ ជោតិបាលស្ស
មាណាវស្ស ឧស្សន្នភោជនំ ។ ឃរំ ភោតំ ខោ ភោ
ជោតិបាលោ មាណាវោ តស្ស បុរិសស្ស បដិស្សុត្វា
យេន កថា និសម្បតិ តេនុបសង្កមិ ឧបសង្កមិត្វា
និសម្បតិនា រញ្ញា សទ្ធិំ សម្មោទិ សម្មោទនីយំ កថំ
សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ
និសិន្នំ ខោ ភោ ជោតិបាលំ មាណាវំ កថា និសម្បតិ
ឯតទវោច អនុសាសតុ ភោ ភវំ ជោតិបាលោ មាណា-
វោ មោ ភោ(១) ភវំ ជោតិបាលោ មាណាវោ(២) អនុសាស-
នីយា បច្ចព្យាហាសិ(៣) បេត្តិកេ តំ ឋានំ ឋបេស្សាមិ(៤)
ភោវិដ្ឋិយេ អភិសំភ្ជិស្សាមីតិ ។ ឃរំ ភោតំ ខោ(៥) ជោតិ-
បាលោ មាណាវោ និសម្បតិស្ស រញ្ញោ បច្ចស្សោសិ ។

---

១ ឱ. ភោតំ ន ទិស្សតិ ។ ២ ឱ. ម. អាណាវោតំ ន ទិស្សតិ ។ ៣ ម. បច្ចព្យា-
ការិ ។ ៤ ឱ. តំ ឋានេ ឋបយិស្សាមិ ។ ម. តំ ឋានេ ។ ៥ ឱ. ខោ ភោ ។
ម. ខោ សោ ។

ទៅដល់ហើយ បានថ្វៃង់ព្រះនុង្ការនេះ នឹងជោតិបាលមាណពថា សូម
សេចក្តីចំរើនមាន ដល់ជោតិបាលមាណពដ៏ចំរើនចុះ ព្រះបាទទិសម្បតិ
មានព្រះនុង្ការឲ្យហៅជោតិបាលមាណពដ៏ចំរើន ព្រះបាទទិសម្បតិចង់ជួប
នឹងជោតិបាលមាណពដ៏ចំរើន ។ ម្នាលអ្នកដ៏ចំរើន ជោតិបាលមាណព
ទទួលតបពាក្យពជបុរសនោះថា អើអ្នកដ៏ចំរើន យ៉ាងនេះហើយ ទើប
ចូលទៅគាល់ព្រះបាទទិសម្បតិ លុះចូលទៅដល់ហើយ ក៏ពោលពាក្យ
ពាក់ព័ន្ធជាមួយនឹងព្រះបាទទិសម្បតិ លុះបញ្ចប់ពាក្យដែលគួរគប្បីកថា នឹង
ពាក្យដែលគួរលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលអ្នកដ៏ចំរើន
លុះជោតិបាលមាណព អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះបាទទិ-
សម្បតិ មានព្រះបន្ទូលយ៉ាងនេះថា ជោតិបាលមាណពដ៏ចំរើន ចូរអ្នក
ប្រឹនប្រដៅយើងចុះ ជោតិបាលមាណពដ៏ចំរើន កុំលះបង់យើងអំពីការ
ប្រឹនប្រដៅឡើយ យើងនឹងតាំងអ្នកក្នុងតំណែងជារដ្ឋដំណែលបិតាអ្នក
យើងនឹងស្រោចទឹកអ្នកក្នុងទីជារបស់គោរិន្ទព្រាហ្មណ៍ ។ ជោតិបាល-
មាណព ទទួលព្រះបន្ទូលព្រះបាទទិសម្បតិថា ព្រះករុណាវិសេស ។

อถ ขฺวาหํ โภ[๑] ภนฺเท ยสฺมึ สมเย ปฏิกฺกนฺตา มาตุคาม
โคตมี อภิสปฺปิ[๒] เหฏฺฐาโภ ปาสาเท ปมาเท ฯ
อภิสปฺปิตฺวา ปฏิกฺกนฺตา มาตุคาม โคตมี เหฏฺฐา-
โภ ปาสาเท ปมชฺชิ โย ปมชฺเชยฺย ปาจิตฺติยนฺติ อตฺถิ อนุสาสนี
ติปิ[๓] อตฺถิ อนุสาสนีติ ยสฺมึ สมเย ปฏิกฺกนฺตา มาตุคาม โคต-
มี อตฺถิ อนุสาสนี ติปิ อตฺถิ นานุสาสนีติ ยสฺมึ สมเย ปฏิกฺกนฺตา
มาตุคาม โคตมี อภิสปฺปิตฺวา ปฏิกฺกนฺตา มาตุคาม โคตมี อภิสปฺปิตฺวา
ยสฺมึ สมเย ปฏิกฺกนฺตา มาตุคาม โคตมี นาภิสปฺปิ ติปิ มาตุคาม โคตมี
นาภิสปฺปิตฺวา ฯ ตเทหิ มนุสฺสา ฆรมาหึสุ โคตมิยา
ฆรา โภ ปฺรพฺรูหฺมณา มหาโคตมิยา ฆรา โภ ปฺรพฺรูห-
ณาติ ฯ สมิตา ขฺวาหํ[๔] โภ โคตมิยา ปริยายเยน ปา-
ฏิหาริยสฺส มาณวสฺส มหาโคตมิโยวาทสฺส[๕] สมฺมา
ทนฺตาติ ฯ

---

๑ ม. ภวติ ส ทิสฺสติ ฯ ๒ ม. อภิปตฺวาติ ฯ ๓ ฉ. เต ฯ ๔ ฉ. ฌติ ฯ
๕ ฉ. มหาโคตมิโยวาทสฺส มหาโคตมิโยวาทสฺส ฯ ม. โคตมิโยวาทสฺส .. .. ฯ

ម្នាលអ្នកដ៏ចំរើន លុះព្រះបាទទិសម្បតិ ទ្រង់ស្រោចទឹកជោតិបាល-
មាណព ក្នុងតំណែងជាគោវិន្ទព្រាហ្មណ៍ ទ្រង់តាំងជោតិបាលមាណព
ក្នុងតំណែងជាជំណែលបិតា ។ ជោតិបាលមាណព ដែលព្រះពជា
ទ្រង់ស្រោចទឹក ក្នុងទីជារបស់គោវិន្ទព្រាហ្មណ៍ ទ្រង់តាំងជាជំណែល
បិតាហើយ តែងប្រៀនប្រដៅនូវសេចក្តីពាំងឡាយ ដែលបិតាបានប្រៀន
ប្រដៅហើយ ដល់ព្រះពជានោះផង មិនបានប្រៀនប្រដៅ នូវសេចក្តី
ពាំងឡាយ ដែលបិតាមិនបានប្រដៅដល់ព្រះពជានោះផង បានចាត់ចែង
ការងារពាំងឡាយ ដែលបិតាបានចាត់ចែងហើយ ដល់ព្រះពជានោះផង
មិនបានចាត់ចែងនូវការងារពាំងឡាយ ដែលបិតាមិនបានចាត់ចែងហើយ
ដល់ព្រះពជានោះផង ។ មនុស្សពាំងឡាយ ក៏នាំគ្នានិយាយពីដំណើរ
នោះថា អើហ្ន៎ មើលចុះគោវិន្ទព្រាហ្មណ៍ អើហ្ន៎ មើលចុះមហាគោវិន្ទ-
ព្រាហ្មណ៍ ។ ម្នាលអ្នកដ៏ចំរើន ជោតិបាលមាណព ក៏បានឈ្មោះថា
មហាគោវិន្ទព្រាហ្មណ៍ ដោយបរិយាយនេះ យ៉ាងនេះឯង ។

[๕๘] អថខោ គោ មហាគោវិន្ទោ ព្រាហ្មណោ យេន តេ ឆ ឥត្ថិយោ តេនុបសង្កមិ ឧបសង្កមិត្វា តេ ឆ ឥត្ថិយេ ឯតទវោច ឧិសម្បតំ ខោ(๑) គោ ភជាជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធុកតោ វយោអនុប្បត្តោ គោ ឆុ ខោ បន គោ ជានាតំ ជីវិតានំ(๒) ឋានំ ខោ បនេតំ វិជ្ជតិ យំ ឧិសម្បតិម្ហិ វញ្ញេ គាលកតេ ភជ-គ្គាវេ វេណ្ឌុំ ភជបុត្តំ វជ្ជ អតិសិញ្ចេយ្យុំ អាយន្តុ គោឆ្ដោ យេន វេណ្ឌុ ភជបុត្តោ តេនុបសង្កមថ ឧប-សង្កមិត្វា វេណ្ឌុំ ភជបុត្តំ ឯវំវាទេថ មយំ ខោ(៣ គោតោ វេណ្ឌុស្ស សមាយោ បិយោ មនាបោ អប្បដិកូលោ យំសុខោ ភវំ តំសុខា មយំ យំទុក្ខោ ភវំ តំទុក្ខា មយំ

---

๑ ឆ. ខោតិ ន ទិស្សតិ ។ ๒ ម. ជីវិតំ ។ ๓ ឆ. ខោតិ ន ទិស្សតិ ។

(๕๘) ម្នាលអ្នកដ៏ចំរើន គ្រានោះ មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ក្សត្រខាំង ๖ អង្គនោះ លុះចូលទៅដល់ហើយ បានក្រាបបង្គំទូលក្សត្រខាំង ๖ អង្គនោះ យ៉ាងនេះថា បពិត្រព្រះអង្គម្ចាស់ដ៏ចំរើន ព្រះបាទទិសម្បតិ ទ្រង់ព្រះជរាចាស់គ្រាំគ្រា ទ្រង់ព្រះជន្មមកយូរឆ្នាំហើយ មានព្រះជន្ម កំជ្រុលចូលមកកន្លងបច្ឆិមវ័យហើយ បពិត្រព្រះអង្គម្ចាស់ដ៏ចំរើន នរណាហ្ន៎ នឹងដឹងនូវជីវិតបាន គាលបើព្រះបាទទិសម្បតិ ទ្រង់ទិវង្គតទៅ ពួកអ្នកពាជការគប្បីអភិសេកវេណុពាជបុត្រ ក្នុងពាជសម្បត្តិ ហេតុនេះ រមែងមាន សូមព្រះអង្គម្ចាស់ខាំងឡាយដ៏ចំរើនស្តេចមក សូមព្រះអង្គម្ចាស់ខាំងឡាយ ទៅគាល់ព្រះវេណុពាជបុត្រ លុះចូលទៅដល់ហើយ ត្រូវថ្លែងសេចក្តីចំពោះព្រះវេណុពាជបុត្រ យ៉ាងនេះថា ពួកយើងជាសំឡាញ់ ជាទីស្រឡាញ់ ជាទីពេញចិត្ត មិនដាច់ខ្ពើមរអើម នៃព្រះវេណុពាជបុត្រដ៏ចំរើនឡើយ ព្រះអង្គដ៏ចំរើនមានសុខយ៉ាងណា ពួកយើងមានសុខយ៉ាងនោះ ព្រះអង្គដ៏ចំរើនមានទុក្ខ យ៉ាងណា ពួកយើងមានទុក្ខ យ៉ាងនោះ

ឥសម្បតិ ខោ (១) គោ កជា ដិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ គោ ទុ ខោ បន គោ ជាជាតិ ជីវិតាឝំ ហានំ ខោ បនេតំ វិជ្ជតិ យំ ឥសម្បតិមិ វញ្ញេ គាលគតេ កជកត្តារេ ភវិំ វេណុំ វជ្ជេ អកិសវិញ្ញេយ្យុំ សវេ ភវិ វេណុ វជ្ជិ លភេថ សំវិភជេថ ឥមា វជ្ជេជាតិ ។ ឯវំ គោតិ ខោ(២) តេ ឆ ខត្តិយោ មហាគោវិន្ទស្ស ព្រាហ្មណស្ស បដិស្សុត្វា យេន វេណុ កជបុត្តោ តេនុបសង្កមិសុ ឧបសង្កមិត្វា វេណុំ កជបុត្តំ ឯតទវោចុំ មយំ ខោ (៣) គោតោ វេណុស្ស សហាយោ បិយោ មនាបោ អប្បដិក្កូលោ យំសុខោ ភវំ តំសុខា មយំ យំទុក្ខោ ភវំ តំទុក្ខា មយំ ឥសម្បតិ ខោ គោ កជា ដិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ

---

១ ឱ. ភោតិ ឥត្តំ ។ ២ ឱ. ភោ ភោ ។ ៣ ឱ. ភោតិ ឥត្តំ ។

បពិត្រព្រះអគ្គម្ចាស់ដ៏ចំរើន ព្រះបាទទិសម្បតិ ទ្រង់ព្រះជរាចាស់គ្រាំគ្រា ទ្រង់ព្រះជន្មមកយូរឆ្នាំហើយ មានព្រះជន្ម ក៏ជ្រុលចូលមកកន្លងបច្ឆិមវ័យហើយ បពិត្រព្រះអគ្គម្ចាស់ដ៏ចំរើន នរណាហ្ន៎ នឹងដឹងជីវិតបាន កាលបើព្រះបាទទិសម្បតិ ទ្រង់ទិវង្គតទៅហើយ ពួកអ្នករាជការ គប្បីអភិសេកព្រះរេណុកដបុត្រដ៏ចំរើនក្នុងរាជសម្បត្តិ ហេតុនេះរមែងមាន បើព្រះរេណុកដបុត្រដ៏ចំរើន ត្រូវបានរាជសម្បត្តិ សូមព្រះអង្គចែករាជសម្បត្តិដល់យើងខ្ញុំទាំងឡាយផង ។ ក្សត្រទាំង ៦ អង្គនោះ ទទួលពាក្យរបស់មហាគោវិន្ទព្រាហ្មណ៍ថា ម្នាលអ្នកដ៏ចំរើន មែនហើយ ទើបចូលទៅគាល់រេណុកដបុត្រ លុះចូលទៅដល់ហើយ ក្រាបទូលរេណុកដបុត្រ យ៉ាងនេះថា យើងទាំងឡាយ ជាសំឡាញ់ ជាទីស្រឡាញ់ ជាទីពេញចិត្ត មិនជាទីខ្ពើមរអើម នៃព្រះរេណុកដកុមារ ដ៏ចំរើនឡើយ ព្រះអង្គដ៏ចំរើន មានសុខយ៉ាងណា ពួកយើងមានសុខ យ៉ាងនោះ ព្រះអង្គដ៏ចំរើន មានទុក្ខយ៉ាងណា ពួកយើងមានទុក្ខ យ៉ាងនោះ បពិត្រព្រះអគ្គម្ចាស់ដ៏ចំរើន ព្រះបាទទិសម្បតិ ទ្រង់ព្រះជរាចាស់គ្រាំគ្រា ទ្រង់ព្រះជន្មមកយូរឆ្នាំហើយ មានព្រះជន្ម ក៏ជ្រុលចូលមកកន្លងបច្ឆិមវ័យហើយ បពិត្រ

កោ ន្តុ ខោ បន កោ ជានាតិ ដីវិតានំ ឋានំ ខោ បនេតំ វិជ្ជតិ យំ ឥសម្បតិមិ រញ្ញោ កាលេកតេ ភដកត្តារោ អវន្តិំ វេណុំ រជ្ជេ អភិសិញ្ចេយ្យុំ សចេ ភវំ វេណុ រជ្ជំ លភេថ សំវិភជេថ នោ រជ្ជេនាតិ ។ កោ ន្តុ ខោ កោ អញ្ញោ មម វិជិតេ សុខំ ភវេយ្យ-ថ(๑) អញ្ញត្រ ភវន្តេហិ សចាហំ កោ រជ្ជំ លភិស្សាមិ សំវិភជិស្សាមិ ភេ រជ្ជេនាតិ ។ អថខោ កោ អរោ-វត្តានំ អច្ចយេន ភដា ឥសម្បតិ កាលមកាសិ ។ ឥសម្បតិមិ រញ្ញោ កាលេកតេ ភដកត្តារោ វេណុំ ភដបុត្តំ រជ្ជេ អភិសិញ្ចិសុ ។ អភិសិត្តោ វេណុ រជ្ជេ បញ្ចហិ តាមកុណេហិ សមប្បិតោ ស-មង្គិភូតោ បរិចារេតិ ។ អថខោ កោ មហា-កោវិន្ទោ ព្រាហ្មណោ យេន តេ ន ខត្តិយា តេនុប-សង្កមិ ឧបសង្កមិត្វា តេ ន ខត្តិយេ ឯតទវោច

---

๑ ម. សុខមេធេយ្យាថ ។ ម. សុខ ភវិស្សាថ ។

ព្រះអង្គម្ចាស់ដ៏ចំរើន នរណា ហ្ន៎ នឹងដឹងនូវដំរិតបាន កាលបើព្រះបាទទិ-
សម្បតិ ទ្រង់ទិវង្គតទៅហើយ ពួកអ្នកពាជការ គប្បីអភិសេកព្រះវេណុពាជ-
បុត្រដ៏ចំរើន ក្នុងពាជសម្បត្តិ ហេតុនេះរមែងមាន បើព្រះវេណុពាជបុត្រ
ដ៏ចំរើន ត្រូវបានពាជសម្បត្តិហើយ សូមព្រះអង្គចែកពាជសម្បត្តិដល់យើង
ខ្ញុំតាំងឡាយផង ។ វេណុពាជបុត្រ ទ្រង់តបថា ម្នាលអ្នកដ៏ចំរើន
បើក្រែអំពីអ្នកដ៏ចំរើនតាំងឡាយហើយ អ្នកដទៃណា នឹងផ្តល់សេចក្តី
សុខឲ្យកើតឡើង ក្នុងដែនរបស់យើងបាន ម្នាលអ្នកដ៏ចំរើន បើយើងនឹង
បានពាជសម្បត្តិ យើងនឹងចែកពាជសម្បត្តិ ដល់អ្នកតាំងឡាយផងដែរ ។
ម្នាលអ្នកដ៏ចំរើន លុះថ្ងៃនឹងយប់តាំងឡាយ កន្លងទៅហើយ ព្រះបាទ
ទិសម្បតិ ក៏ទ្រង់ទិវង្គតទៅ ។ កាលបើព្រះបាទទិសម្បតិ ទ្រង់ទិវង្គតទៅ
ហើយ ពួកអ្នកពាជការ ក៏បានអភិសេកព្រះវេណុពាជបុត្រក្នុងពាជសម្បត្តិ ។
លុះព្រះវេណុពាជបុត្រ បានអភិសេកដោយពាជសម្បត្តិហើយ ទ្រង់ស្អប់ស្អល់
មូលមិត្រផ្តេកផ្តិតដោយកាមគុណតាំង ៥ ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង
មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ក្សត្រតាំង ៦ អង្គនោះ លុះចូល
ទៅដល់ហើយ ទើបក្រាបទូលក្សត្រតាំង ៦ អង្គនោះ យ៉ាង ភ

ឯសមេ្ពតំ ខោ គោ រាជា គាលគតោ អភិសិត្តោ វេណុ រដ្ឋេន រញ្ញេហិ គាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេតិ គោ ឧ ខោ បន គោ ជានាតិ មធនិយោ គាមោ អាយត្តេ គោត្តោ យេន វេណុ រាជា តេនុបសង្កមថ ឧបសង្កមិត្វា វេណុំ រាជានំ ឯវំ វទេថ ឯសមេ្ពតំ ខោ គោ រាជា គាលគតោ អភិសិត្តោ គុរុ វេណុ រដ្ឋេន សរតំ គុរុ តំ វចនន្តិ ។ ឯវំ គោតំ ខោ(๑) តេ ឧត្តិយា មហោសាលេ ខត្តិយេ ព្រាហ្មណេ គហបតិកេ បដិសុត្វា យេន វេណុ រាជា តេនុបសង្កមិំសុ ឧបសង្កមិត្វា វេណុំ រាជានំ ឯតទវោចុំ ឯសមេ្ពតំ ខោ គោ រាជា គាលគតោ អភិសិត្តោ គុរុ វេណុ រដ្ឋេន សរតំ គុរុ តំ វចនន្តិ ។ សរាមហំ គោ តំ វចនន្តិ(๒) ។

---

๑ ឱ. ម. ខោ គោ ។ ๒ ឱ. វិបរិ ។

បពិត្រព្រះអគ្គម្ចាស់ដ៏ចំរើន ព្រះបាទទិសម្បតិ ទ្រង់ទិវង្គតទៅហើយ ព្រះបាទរណៈដែលបានអភិសេកដោយពាជសម្បត្តិហើយ ព្រះអង្គក៏ស្អប់ស្អល់មូលមិត្រផ្តេកផ្តិត ដោយកាមគុណទាំង ៥ បពិត្រព្រះអង្គម្ចាស់ដ៏ចំរើន នរណាហ៊ានឆ្ងាយ (រឿងនេះបាន ព្រោះ) កាមារម្មណ៍ទាំងឡាយ សុទ្ធតែជាសភាវៈនាំឲ្យស្រវឹង សូមឲ្យព្រះអង្គម្ចាស់ដ៏ចំរើនទាំងឡាយ ស្តេចមកនឹងចូលទៅគាល់ព្រះបាទរណៈ លុះចូលទៅដល់ហើយ ចូរក្រាបទូលព្រះបាទរណៈយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទទិសម្បតិ ទ្រង់ទិវង្គតហើយ ព្រះបាទរណៈដ៏ចំរើន បានទទួលអភិសេកដោយពាជសម្បត្តិហើយ ព្រះអង្គដ៏ចំរើន រលឹកឃើញពាក្យនោះដែរឬ ។ ពួកក្សត្រទាំង៦ អង្គនោះទទួលពាក្យមហាគោវិន្ទព្រាហ្មណ៍ថា ម្នាលអ្នកដ៏ចំរើន មែនហើយ រួចក៏ចូលទៅគាល់ព្រះបាទរណៈ លុះចូលទៅដល់ហើយ បានក្រាបទូលព្រះបាទរណៈយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទទិសម្បតិ ទ្រង់ទិវង្គតហើយ ព្រះបាទរណៈដ៏ចំរើន បានទទួលអភិសេកដោយពាជសម្បត្តិហើយ តើព្រះអង្គដ៏ចំរើន រលឹកឃើញពាក្យនោះដែរឬ ។ ព្រះបាទរណៈមានព្រះពាសុក្តាថា ម្នាលអ្នកដ៏ចំរើន យើងរលឹកឃើញពាក្យនោះដែរ ។

តោ ន្តុ ខោ តោ បហោតិ តំ មហាមហឹ ឧត្តរេន អាយតំ ឧត្តរិណេន សកដមុខំ សត្តធា សមំ សុវិភត្តំ វិភជិតុន្តិ ។ តោ ន្តុ ខោ តោ អញ្ញោ បហោតិ អញ្ញត្រ មហាតោវិន្ទេន ព្រាហ្មណោតិ ។ អថ ខោ តោ វេណ្ហុ រាជា អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស យេន មហាតោវិន្ទោ ព្រាហ្មណោ តេនុបសង្កម ឧបសង្កមិត្វា មហាតោវិន្ទំ ព្រាហ្មណំ ឯវំ វទេហិ រាជា តំ អន្តេ វេណ្ហុ អាមន្តេតីតិ ។ ឯវំ ទេវាតិ ខោ តោ សោ បុរិសោ វេណ្ហុស្ស រញ្ញោ បដិស្សុត្វា យេន មហាតោវិន្ទោ ព្រាហ្មណោ តេនុបសង្កមិ ឧបសង្កមិត្វា មហាតោវិន្ទំ ព្រាហ្មណំ ឯតទវោច រាជា តំ អន្តេ វេណ្ហុ អាមន្តេតីតិ ។ ឯវំ តោតិ ខោ តោ មហាតោវិន្ទោ ព្រាហ្មណោ តស្ស បុរិសស្ស បដិស្សុត្វា

ពួកក្សត្រទាំង ៦ អង្គ គ្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន នរណាហ្ន៎ លុមនទីធ្វើចែកមហាប្រឹថពីនេះ ដែលមានបណ្តាយទៅខាងទិសទក្ខិណ មានមុខដូចជាមុខរនេះ ទៅខាងទិសទក្ខិណ ឲ្យមានចំណែកស្មើគ្នា ជា ៧ ភាគបាន ។ ព្រះបាទវេណុ មានព្រះពាជទន្ធ្នាវថា ម្នាលអ្នកដ៏ចំរើន រៀវលែងតែមហាគោវិន្ទព្រាហ្មណ៍ចេញ អ្នកដទៃណាហ្ន៎ លុមនទីធ្វើចែកបាន ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង ព្រះបាទវេណុ មានព្រះពាជទន្ធ្នារហៅបុរសម្នាក់មកថា ម្នាលអ្នកដ៏ចំរើន ឯងចូរមកនេះ ឯងចូរទៅរកមហាគោវិន្ទព្រាហ្មណ៍ លុះចូលទៅដល់ហើយ ចូរដំកបមហាគោវិន្ទព្រាហ្មណ៍ យ៉ាងនេះថា បពិត្រលោកដ៏ចំរើន ព្រះបាទវេណុ មានព្រះពាជទន្ធ្នារឲ្យហៅលោក ។ ម្នាលអ្នកដ៏ចំរើន បុរសនោះ ទទួលព្រះពាជទន្ធ្នារ នៃព្រះបាទវេណុថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ហើយចូលទៅរកមហាគោវិន្ទព្រាហ្មណ៍ លុះចូលទៅដល់ហើយ បានដំកបមហាគោវិន្ទព្រាហ្មណ៍ យ៉ាងនេះថា បពិត្រលោកដ៏ចំរើន ព្រះបាទវេណុ មានព្រះពាជទន្ធ្នារឲ្យហៅលោក ។ ម្នាលអ្នកចំរើន មហាគោវិន្ទព្រាហ្មណ៍ ទទួលពាក្យរបស់បុរសនោះថា អើអ្នកដ៏ចំរើន

เยน เวณฺหุ ภวา เตนุปสงฺกมิ อุปสงฺกมิตฺวา เวณฺหุนา ราชา สทฺธึ สมฺโมทิ สมฺโมทนียํ กถึ สาราณียํ วีติสาเรตฺวา เอกมนฺตํ นิสีทิ ฯ เอกมนฺตํ นิสินฺโน โข โส[๑] มหาโควินฺโท พฺราหฺมณา เวณฺหุ ภวา เอตทโวจ เอตุ ภวं โควินฺโท สมํ มหาปถวึ อุตฺตเรน อายตึ ทกฺขิเณน สกฺกปุถึ สณฺฐหา สมึ สุวิภตฺตึ วิภชตฺวาติ ฯ เอวं โสติ โข[๒] มหาโควินฺโท พฺราหฺมณา เวณฺหุสฺส ราโญ ปฏิสฺสุตฺวา สมึ มหาปถวึ อุตฺตเรน อายตึ ทกฺขิเณน สกฺกปุถึ สณฺฐหา สมึ สุวิภตฺตึ วิภชิ สพฺพานิ สกฺกปุถานิ ปฏฺฐเปสิ[๓] ฯ ตตฺร สุทึ มญฺเญ เวณฺหุสฺส ราโญ เอวมาหุ

(๕๙) ธนปุปฺผา ปาลิภทฺทกา

อสฺสกายนา โธตรถา

๑-๒ ฉ. ภวติ สตฺถา ฯ ๓ ฉ. อฏฺฐเปสิ ฯ

ហើយចូលទៅគាល់ព្រះបាទវេណុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យ
ពត់ពាត់ សំណោះសំណាលទៅកព្រះបាទវេណុ លុះបញ្ចប់ពាក្យដែលគួរ
រីករាយនឹងពាក្យដែលគួរលើកៈហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលអ្នក
ដ៏ចំរើន លុះមហាគោវិន្ទព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះបាទ
វេណុមានព្រះរាជឫទ្ធានុភាពយ៉ាងនេះថា គោវិន្ទព្រាហ្មណ៍ដ៏ចំរើន ចូរអញ្ជើញ
មកចែកមហាប្រឹថពីនេះ ដែលមានបណ្តាយទៅខាងទិសទក្ខិណ មានមុខ
ដូចជាមុខរនេះ ទៅខាងទិសទក្ខិណ ឲ្យមានចំណែកស្មើគ្នាជា ៧ ភាគ ។
ម្នាលអ្នកដ៏ចំរើន មហាគោវិន្ទព្រាហ្មណ៍ ទទួលព្រះបន្ទូលព្រះបាទវេណុ
ថា បពិត្រព្រះសម្មតិទេព ព្រះគុណាវិសេស ហើយក៏ចែកមហា-
ប្រឹថពីនេះ ដែលមានបណ្តាយទៅខាងទិសទក្ខិណ មានមុខដូចជាមុខរនេះ
ទៅខាងទិសទក្ខិណ ឲ្យមានចំណែកស្មើគ្នាជា ៧ ភាគ ហើយតំកល់
ទុកនូវដែនតំបន់អស់ ឲ្យមានមុខដូចជាមុខរនេះ ។ មានសេចក្តីដំណាល
ក្នុងរឿងនោះថា ជនបទ របស់ព្រះបាទវេណុ នៅត្រង់កណ្តាល ។

(៥៩) គោវិន្ទព្រាហ្មណ៍ បានសាងទីក្រុងតំបន់ ៧ នេះ គឺ
ក្រុងទន្តបុរៈ សម្រាប់ពួកអ្នកដែនកាលិង្គៈ ១ ក្រុងបោតនៈ

สุตฺตนฺตปิฏเก ขุทฺทกนิกายสฺส มหานิทฺเทโส

มาตาปิตฺตุ(๑) อาทีนิ

สาธิภาคญฺจ ภาตุกานิ(๒)

มิตฺตามจฺจา จ ญาตโย

จตฺตาโร อาสฺเสสุ มาตาปิตา

พาหณาสี จ กาสีนิ

ฆาเต สาวิฏฺฐมาตาปิตานิ ฯ

[๖๐] อถโข สา เสฏฺฐิธีตา จ ทาสิยา ยถาสเกน ลาภเกน อตฺตมนา อโหสุ๋ ปริปุณฺณสงฺกปฺปา ยาวตา หิ โลเก อโหสิ สทฺธิตา ยาว อาคารฏฺฐานา(๓) อภิปฺปสนฺนา ยาว อภิสตฺตานา ตาว โลเก ลงฺฆิตา ฯ

[๖๑] สตฺตภู พฺรหฺมเทวา จ

วิสฺสภู ภารเทว สหา

เวณฺหุ เทฺว ฉตฺรวฏฺฐา จ

ตถาสุ สตฺต ภารภาติ(๔) ฯ

ปรมภาณวารา สตฺตฺตา ฯ

---

๑ ม. ปเหสยิ ฯ ๒ ฉ สาธิภาคญฺจ ภาตุกานิ ฯ ม. สาธิภาคญฺจ จ ภาตุกานิ ฯ ๓ ฉ. ม. อาคารฏฺฐานา ยาว ฯ ๔ ฉ ภารภาติ ฯ ม. ภารหาติ ฯ

សម្រាប់ពួកអ្នកដែនអស្សកៈ ១ ក្រុងមាហិស្សតិ សម្រាប់ពួកអ្នកដែនអវន្តិ ១ ក្រុងពោរកៈ សម្រាប់ពួកអ្នកដែនសោបិរៈ ១ ក្រុងមិថិលា សម្រាប់ពួកអ្នកដែនវិទេហៈ ១ ក្រុងចម្បាដែលកសាង ក្នុងដែនឈ្មោះអង្គៈ ១ ក្រុងពារាណសី សម្រាប់ពួកអ្នកដែនកាសី ១ ។

(៦០) ម្នាលអ្នកដ៏ចំរើន គ្រានោះឯង ក្សត្រទាំង ៦ អង្គនោះ ទ្រង់សព្វព្រះទ័យ មានសេចក្តីត្រេកអរពេញបរិបូណ៌ហើយ ដោយលាភគួរដល់ព្រះអង្គថា នុ៎ះ របស់ណា ដែលពួកយើងត្រេកអរហើយ របស់ណា ដែលពួកយើងប៉ុនប៉ងសំដៅយកហើយ របស់ណា ដែលពួកយើងកត់សំគាល់ទុកហើយ របស់នោះ ។ ក៏ពួកយើងបានអស់ហើយ ។

(៦១) ព្រះបាទសត្តភូ អង្គ ១ ព្រះបាទព្រហ្មទត្ត អង្គ ១ ព្រះបាទវេស្សភូ អង្គ ១ ព្រមទាំងព្រះបាទករតៈ អង្គ ១ ព្រះបាទរេណុ អង្គ ១ ព្រះបាទឆតរដ្ឋ ២ ព្រះអង្គទៀត រួមបានជាស្តេចគ្រប់គ្រងដែនដី មាន ៧ ព្រះអង្គ ក្នុងគ្រានោះ ។

ចប់ បឋមភាណវារៈ ។

[๖๒] อถโข เต ขตฺติยา เยน มหา-โควินฺโท พฺราหฺมโณ เตนุปสงฺกมึสุ อุปสงฺกมิตฺวา มหาโควินฺทํ พฺราหฺมณํ เอตทโวจุ๋ ยถา โข(๑) ภวํ โควินฺโท วณฺณสฺส วญฺโญ สหายโย ปิโยว มญฺญโถ อมฺหากมฺปิ ตถารูปา ขฺวาสฺส ภวนฺตา โควินฺโท พฺราหฺมณา(๒) อมฺหากมฺปิ สหายโย ปิโยว มญฺญโถ อมฺหากมฺปิ ตถารูปา ขฺวาสฺส อนุสาสนฺตา โข ภวนฺโต โควินฺโท พฺราหฺมณา(๓) มา โข ภวนฺโต โควินฺโท พฺราหฺมณา(๔) อนุสาสนิยา ปจฺจุพฺยาหาสีติ ฯ เอวํ ภทนฺเต โข เต(๕) มหา-โควินฺโท พฺราหฺมณา เตสํ ขตฺติยานํ ปจฺจสฺโสสิ(๖) ปจฺจสฺโสสิ ฯ อถโข เต มหา-โควินฺโท พฺราหฺมณา อนุสาสนิยา(๗) สตฺต จ ภาชาโน ขตฺติเย ปุจฺฉาภิสิตฺเต รชฺเช(๘) อนุสาสิ สตฺต จ พฺราหฺมณมหาสาเล สตฺต จ ฉมา-ตกสตานิ มนฺเต ภาเชสิ ฯ อถโข เต(๙)

---

๑ ฉ. โขตฺถ สตฺติ ฯ ๒-๓-๔ ฉ. ม. พฺราหฺมณาตฺถ สตฺติ ฯ ๕ ม. เต ฯ ๖ ฉ ม. ปุจฺฉาภิสิตฺตาสตฺติ สตฺติ ฯ ๗ ฉ. ม. อนุสาสนิยาตฺถ สตฺติ ฯ ๘ ฉ. ม. รชฺเช ฯ ๙ ม. โขตฺถ สตฺติ ฯ

(៦៦) ម្នាលអ្នកដ៏ចំរើន គ្រានោះឯង ក្សត្រតាំង ៦ អង្គនោះ ចូលទៅរកមហាគោវិន្ទព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏មានព្រះពាដនុដ្ឋារទៅ នឹងមហាគោវិន្ទព្រាហ្មណ៍ យ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន គោវិន្ទព្រាហ្មណ៍ដ៏ចំរើន ជាសំឡាញ់ ជាទីស្រឡាញ់ពេញព្រះទ័យ មិនជាទីខ្ពើមរអើម នៃព្រះបាទវេណុ យ៉ាងណាមិញ គោវិន្ទព្រាហ្មណ៍ដ៏ចំរើន ក៏ជាសំឡាញ់ ជាទីស្រឡាញ់ ពេញចិត្ត មិនជាទីខ្ពើមនៃពួកយើងយ៉ាងនោះដែរ គោវិន្ទព្រាហ្មណ៍ដ៏ចំរើន ចូរប្រៀនប្រដៅពួកយើងចុះ គោវិន្ទព្រាហ្មណ៍ដ៏ចំរើន កុំលះបង់យើងអំពីការប្រៀនប្រដៅឡើយ ។ ម្នាលអ្នកដ៏ចំរើន មហាគោវិន្ទព្រាហ្មណ៍ ទទួលស្តាប់ព្រះពាដនុដ្ឋារ ក្សត្រតាំង ៦ ព្រះអង្គនោះ ដែលបានមុទ្ធាភិសេកហើយថា ព្រះករុណាវិសេស ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ក៏ប្រៀនប្រដៅពួកក្សត្រតាំង ៧ ព្រះអង្គ ដែលបានមុទ្ធាភិសេក ដោយពាដសម្បត្តិ ដោយអនុសាសនីផង បានបង្រៀនមន្តដល់ព្រាហ្មណមហាសាល ៧ នាក់ផង នឹងខ្ចាន់ព្រះកេស ៧០០ នាក់ផង ។ ម្នាលអ្នកដ៏ចំរើន

មហាគោវិន្ទស្ស ព្រាហ្មណស្ស អបរេន សមយេន ឱរំ
កលិង្គាណោ កាឡិង្គសេន្ធោ អព្ភុក្កុដ្ឋិ(១) សក្កិ មហា-
គោវិន្ទោ ព្រាហ្មណោ ព្រហ្មានំ បស្សតិ សក្កិ មហា-
គោវិន្ទោ ព្រាហ្មណោ ព្រហ្មុនា សាកច្ឆតិ សល្លបតិ
មន្តេតីតិ ។ អថខោ គោ មហាគោវិន្ទស្ស ព្រាហ្ម-
ណស្ស ឯតទហោសិ មយ្ហំ ខោ ឱរំកលិង្គាណោ កាឡិង្គ-
សេន្ធោ អព្ភុក្កតោ សក្កិ មហាគោវិន្ទោ ព្រាហ្មណោ
ព្រហ្មានំ បស្សតិ សក្កិ មហាគោវិន្ទោ ព្រាហ្មណោ
ព្រហ្មុនា សាកច្ឆតិ សល្លបតិ មន្តេតីតិ ឯ ខោ
បនាហំ ព្រហ្មានំ បស្សាមិ ឯ ព្រហ្មុនា សាកច្ឆាមិ
ឯ ព្រហ្មុនា សល្លបេមិ(២) ឯ ព្រហ្មុនា មន្តេមិ សុតំ
ខោ បន មេតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ
អាចរិយបាចរិយានំ កាសមាឡានំ យោ វស្សូបេ
ឋត្តាភេ មាសេ បដិសល្លីយតិ កេសុលោមំ ឈានំ ឈា-
យតិ សោ ព្រហ្មានំ បស្សតិ ព្រហ្មុនា សាកច្ឆតិ

---

១ ឱ. អព្ភុគ្គញ្ជិ ។ ២ ឱ.ម. សល្លបាមិ ។

កាលជាខាងក្រោយមក កិត្តិសព្ទដ៏ពីរោះ របស់មហាគោវិន្ទព្រាហ្មណ៍ លឺឮខ្ចរខ្ចាយថា មហាគោវិន្ទព្រាហ្មណ៍ អាចឃើញព្រហ្មដោយផ្ទាល់ខ្លួន មហាគោវិន្ទព្រាហ្មណ៍ អាចសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មដោយផ្ទាល់ខ្លួនបាន ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ មានសេចក្តីត្រិះរិះយ៉ាងនេះភ្លាម កិត្តិសព្ទដ៏ពីរោះ របស់អាត្មាអញ លឺឮខ្ចរខ្ចាយទៅយ៉ាងនេះថា មហាគោវិន្ទព្រាហ្មណ៍ អាចឃើញព្រហ្មដោយផ្ទាល់ខ្លួន មហាគោវិន្ទព្រាហ្មណ៍ អាចសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្ម ដោយផ្ទាល់ខ្លួនបាន តែអាត្មាអញមិនបានឃើញព្រហ្មសោះ មិនអាចសាកសួរ ជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លង ជាមួយនឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្មទេ ប៉ុន្តែអាត្មាអញធ្លាប់ឮពាក្យនេះ របស់ព្រាហ្មណ៍ចាស់ៗ មានអាយុច្រើន ជាអាចារ្យប្រចាំទលើអាចារ្យ និយាយគ្នាថា បុគ្គលណា សម្ងំនៅក្នុងវេជ្ជរភ្លៀងអស់ ៤ ខែ ហើយពិចារណានូវតំណាឈាន បុគ្គលនោះ នឹងឃើញព្រហ្ម នឹងសាកសួរ

សល្ហវតំ មន្តីតំ យន្តមាហំ វស្សិកេ ចតុ-
រោ មាសេ បដិសល្លីយេយ្យំ តរុណំ ឈានំ ឈាយេ-
យ្យន្តិ ។ អថខោ(1) មហាគោវិន្ទោ ព្រាហ្មណោ យេន
វេណុ រាជា តេនុបសង្កមិ ឧបសង្កមិត្វា វេណុំ រាជានំ
ឯតទវោច មយ្ហំ ខោ តោ រាជវំតលក្ខណោ តិត្តិសទ្ទោ
អព្ភុក្កតោ សត្តិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មានំ
បស្សតិ សត្តិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មុនា
សាកច្ឆតិ សល្ហវតំ មន្តីតំ ន ខោ បនាហំ
តោ ព្រហ្មានំ បស្សាមិ ន ព្រហ្មុនា សាកច្ឆាមិ ន
ព្រហ្មុនា សល្ហវេមិ ន ព្រហ្មុនា បន្តេមិ សុតំ ខោ
បន មេតំ ព្រាហ្មណានំ វុឌ្ឍានំ មហាសាលានំ អាចរិ-
យបាចរិយានំ ភាសមានានំ យោ វស្សិកេ ចតុរោ
មាសេ បដិសល្លីយតិ តរុណំ ឈានំ ឈាយតិ សោ
ព្រហ្មានំ បស្សតិ ព្រហ្មុនា សាកច្ឆតិ សល្ហវតំ

---

1 ខ. ម. អថវោ តោ ។

និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន បើដូច្នោះ គួរតែអាត្មាអញ
សម្ងំនៅតង់ដូវក្រៀងអស់ ៤ ខែ ពិចារណានូវតម្កុណាឈាន ។ គ្រានោះ
ឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ព្រះបាទវេណុ លុះចូលទៅដល់
ហើយ បានក្រាបទូលព្រះបាទវេណុ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន
កិត្តិសព្ទដ៏ពីរោះរបស់ខ្ញុំព្រះអង្គ ល្បីឮខ្ចរខ្ចាយទៅយ៉ាងនេះថា មហាគោវិន្ទ-
ព្រាហ្មណ៍ អាចឃើញព្រហ្មដោយផ្ទាល់ខ្លួន មហាគោវិន្ទព្រាហ្មណ៍ អាច
សាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្ម ដោយផ្ទាល់ខ្លួនបាន
បពិត្រព្រះអង្គដ៏ចំរើន តែខ្ញុំព្រះអង្គមិនបានឃើញព្រហ្មសោះទេ មិនបាន
សាកសួរ ជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លងជាមួយនឹងព្រហ្ម មិន
បានប្រឹក្សា ជាមួយនឹងព្រហ្មទេ ប៉ុន្តែខ្ញុំព្រះអង្គធ្លាប់បានឮពាក្យព្រាហ្មណ៍
ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យ និយាយគ្នាថា
បុគ្គលណាសម្ងំនៅតង់ដូវក្រៀងអស់ ៤ ខែ ពិចារណា នូវតម្កុណាឈាន
បុគ្គលនោះ នឹងឃើញព្រហ្មបាន សាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយ

បន្តេតីតំ ឥច្ឆាមហំ ភោ វាសដ្ឋេតេ ចត្តារោ មាសេ បដិសល្លីយិតុំ តរុណំ ឈានំ ឈាយិតុំ នម្ហិ តេនច ខុបសង្កមិតព្ពោ អញ្ញត្រ ឯតេន តត្តាហារេនាតិ(១) ។ យស្សញ្ញានិ តវំ តោវិជ្ជោ តាលំ មញ្ញតីតិ ។ អថខោ មហាតោវិជ្ជោ ព្រាហ្មណោ យេន តេ ន ទ្ធត្តិយា តេនុបសង្កមិ ឧបសង្កមិត្វា តេ ន ទ្ធត្តិយេ ឯតទវោច មយ្ហំ ខោ តេ(២) ឯវំតរុណ្យាណោ តិត្តិសន្តោ អភុក្ខតោ សត្តិ មហាតោវិជ្ជោ ព្រាហ្មណោ ព្រហ្មានំ បស្សតិ សក្តិ មហាតោវិជ្ជោ ព្រាហ្មណោ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ មន្តេតីតិ ន ខោ បនាហំ តេ(៣) ព្រហ្មានំ បស្សាមិ ន ព្រហ្មុនា សាកច្ឆេមិ ន ព្រហ្មុនា សល្លបេមិ ន ព្រហ្មុនា មន្តេមិ សុតំ ខោ បន មេតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ យោ វាសដ្ឋេតេ ចត្តារោ មាសេ បដិសល្លីយតិ តរុណំ ឈានំ ឈាយតិ សោ

---

១ ម. ភត្តាភិហារេនាតិ ។ ២-៣ ម. ភោតិ នត្ថិ ។

នឹងព្រហ្មបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គប្រាថ្នា ដើម្បីនឹងសម្ងំ
នៅក្នុងរដូវក្តៅអស់ ៤ ខែ ដើម្បីពិចារណា នូវតុណាឈាន មិន
ត្រូវឲ្យអ្នកណាមួយ ចូលទៅរកខ្ញុំព្រះអង្គឡើយ រៀវលែងតែបុគ្គលម្នាក់
ជាអ្នកនាំអាហារទៅឲ្យ ។ ព្រះបាទវេណុ មានព្រះរាជឫទ្ធារថា គោវិន្ទ-
ព្រាហ្មណ៍ដ៏ចំរើន សំគាល់នូវកាលគួរកុងកាលឥឡូវនេះចុះ ។ គ្រានោះឯង
មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ក្សត្រទាំង ៦ អង្គនោះ លុះចូលទៅ
ដល់ហើយ បានក្រាបទូលក្សត្រទាំង ៦ អង្គនោះ យ៉ាងនេះថា បពិត្រ
ព្រះអង្គដ៏ចំរើន កិត្តិសព្ទដ៏ពីពេរបស់ខ្ញុំព្រះអង្គ ល្បីពួនខ្ចរខ្ចាយទៅយ៉ាងនេះ
ថា មហាគោវិន្ទព្រាហ្មណ៍ អាចឃើញព្រហ្មដោយផ្ទាល់ខ្លួន មហាគោ-
វិន្ទព្រាហ្មណ៍ អាចសាកសួរ និយាយឆ្លើយតួន ប្រឹក្សាជាមួយនឹងព្រហ្ម
ដោយផ្ទាល់ខ្លួនបាន បពិត្រព្រះអង្គដ៏ចំរើន តែខ្ញុំព្រះអង្គមិនបានឃើញ
ព្រហ្មសោះ មិនបានសាកសួរ ជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយ
តួន ជាមួយនឹងព្រហ្ម មិនបានប្រឹក្សា ជាមួយនឹងព្រហ្មទេ ខ្ញុំព្រះអង្គ
គ្រាន់តែឮសេចក្តីដំណាលនេះ របស់ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ មាន
អាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យ និយាយថា បុគ្គលណាសម្ងំ
នៅក្នុងរដូវក្តៅអស់ ៤ ខែ ពិចារណា នូវតុណាឈាន បុគ្គលនោះ

ព្រហ្មានំ បស្សតិ ព្រហ្មុនា សាកច្ឆតិ សល្លបតិ មន្តេតីតិ ឥច្ចាទិបាឋំ គោ វាសដ្ឋគោត្តេ ចន្តារោ មាសេ បដិ-
សល្លីយិតុំ ការុណិំ ឈានំ ឈាយិតុំ ឧប្បន្នំ គោធម្មំ ឧបសង្កមិតព្ពោ អញ្ញត្រ ឋានេន ភគ្គាហារេនាតិ ។
យស្សញ្ញាយ ភារំ គោវិន្ទោ ភាសំ មញ្ញតីតិ ។ អវ-
ខោ គោ មហាគោវិន្ទោ ព្រាហ្មណោ យេន សត្ត ច ព្រាហ្មណមហាសាលា សត្ត ច ឧទាតកសតានិ តេនុបសង្កមិ ឧបសង្កមិត្វា សត្ត ច ព្រាហ្មណមហា-
សាលេ សត្ត ច ឧទាតកសតានិ ឯតទវោច មយ្ហំ ខោ គោ ឱវាទកប្បា ហោថ អនុសាសនិកប្បា សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មានំ បស្សតិ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មុនា សាកច្ឆតិ សល្លបតិ មន្តេតីតិ ន ខោ បនាហំ គោ ព្រហ្ម-
នំ បស្សាមិ ន ព្រហ្មុនា សាកច្ឆាមិ ន ព្រហ្មុនា សល្លបេមិ ន ព្រហ្មុនា មន្តេមិ សុតំ ខោ បន

មហាគោវិន្ទសូត្រ មហាគោវិន្ទព្រាហ្មណ៍ ចូលទៅរកព្រាហ្មណមហាសាលដោយ
នឹងឃើញនូវព្រហ្មបាន សាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយ
នឹងព្រហ្មបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គប្រាថ្នា ដើម្បីនឹងសម្លឹ
នៅក្នុងរដូវក្តៀងអស់ ៤ ខែ ពិចារណា នូវកុណាឈាន មិនត្រូវឲ្យ
អ្នកណាមួយ ចូលទៅរកខ្ញុំព្រះអង្គឡើយ វៀរលែងតែបុគ្គលម្នាក់ ជាអ្នក
នាំអាហារទៅឲ្យ ។ ក្សត្រគាំង ៦ អង្គ មានព្រះរាជឱង្ការថា គោវិន្ទ-
ព្រាហ្មណ៍ដ៏ចំរើន សំគាល់នូវកាលគួរក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នក
ដ៏ចំរើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅរកព្រាហ្មណមហា-
សាលគាំង ៧ នាក់ នឹងខ្មាន់ព្រះកេសគាំង ៧០០ នាក់ លុះចូលទៅ
ដល់ហើយ បាននិយាយទៅនឹងព្រាហ្មណមហាសាលគាំង ៧ នាក់ នឹង
ខ្មាន់ព្រះកេសគាំង ៧០០ នាក់ យ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន កិត្តិសព្ទ
ដ៏ពីពេរបស់ខ្ញុំ លាន់ខ្ចរខ្ចាយទៅ យ៉ាងនេះថា មហាគោវិន្ទព្រាហ្មណ៍
អាចឃើញព្រហ្មដោយផ្ទាល់ខ្លួន អាចសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សា
ជាមួយនឹងព្រហ្មដោយផ្ទាល់ខ្លួនបាន ម្នាលអ្នកដ៏ចំរើន តែខ្ញុំមិនបានឃើញ
ព្រហ្មសោះ មិនបានសាកសួរ ជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយ
ឆ្លង ជាមួយនឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្មទេ ខ្ញុំគ្រាន់តែឮ

មេតំ ព្រាហ្មណាំ វុទ្ធាំ មហាល្លកាំ អាចរិយបាចរិ-
យានំ កាសមានានំ យោ វស្សិកេ ចត្តារោ មាសេ បដិ-
សល្លីយតិ ករុណាំ ឈានំ ឈាយតិ សេយ្យថិទំ
បឋមំ ព្រហ្មវិហារំ ទុតិយំ ព្រហ្មវិហារំ តតិយំ ព្រហ្មវិហារំ
ចតុត្ថំ ព្រហ្មវិហារំ យថាសុខេ យថាចរិយន្តេ មន្តេ វិត្តាវេន សជ្ឈាយំ
ករោថ អញ្ញមញ្ញំ មន្តេ ភាថេថ នត្ថាមហំ តេ
វស្សិកេ ចត្តារោ មាសេ បដិសល្លីយិតុំ ករុណាំ ឈានំ
ឈាយិតុំ ឧម្ហិ តេនេវ ឧបសង្កមិតព្ពោ អញ្ញត្រ ភ-
គវតា បញ្ហវេយ្យាករណាតិ ។ យស្សុទានិ កាលំ មញ្ញតីតិ ។ អថខោ តេ មហាតេវិជ្ជា
ព្រាហ្មណា យេន ចត្តារីសា ភរិយា សាធិសំយោ តេ-
នុបសង្កមិ ឧបសង្កមិត្វា ចត្តារីសា ភរិយា សាធិសំ-
យោ ឯតទវោច មយ្ហំ ខោ តេតិ ឥរិកលប្បាណា តិដ្ឋ-
សន្តេ អត្តក្ខតោ សក្កិ មហាតេវិជ្ជា ព្រាហ្មណា

សេចក្តីដំណាលនេះ របស់ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យ និយាយថា បុគ្គលណាសម្លាប់ នូវសត្វ ក្នុងរដូវភ្លៀងអស់ ៤ ខែ ពិចារណា នូវកុណាឈាន បុគ្គលនោះ នឹងឃើញព្រហ្មបាន នឹងសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន ម្នាលអ្នកដ៏ចំរើន បើដូច្នោះ ចូរអ្នកតាំងឡាយ ស្វាធ្យាយនូវមន្តតាំងឡាយ តាមដែលបានស្តាប់មកហើយ បានរៀនមកហើយ ដោយពិស្តារចុះ ចូរប្រាប់មន្តតាំងឡាយ ដល់គ្នានឹងគ្នាផងចុះ ម្នាលអ្នកដ៏ចំរើន ខ្ញុំប្រាថ្នា ដើម្បីនឹងសម្លាប់នូវ ក្នុងរដូវភ្លៀងអស់ ៤ ខែ ដើម្បីនឹងពិចារណា នូវកុណាឈាន មិនត្រូវឲ្យអ្នកណាមួយចូលទៅរកខ្ញុំឡើយ លៀវតែបុគ្គលម្នាក់ ជាអ្នកនាំអាហារទៅឲ្យ ។ ព្រាហ្មណមហាសាល នឹងភ្ញាក់ព្រះកេសតាំងនោះ និយាយតបថា គោវិន្ទព្រាហ្មណ៍ដ៏ចំរើន សំគាល់នូវកាលគួរក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង មហាគោវិន្ទ-ព្រាហ្មណ៍ ចូលទៅរកប្រពន្ធតាំង ៤០ នាក់ ដែលមានត្រកូលនឹងជាតិស្មើគ្នា លុះចូលទៅដល់ហើយ បាននិយាយទៅនឹងប្រពន្ធតាំង ៤០ នាក់ ដែលមានត្រកូលនឹងជាតិស្មើគ្នាយ៉ាងនេះថា នែនាងដ៏ចំរើន កិត្តិសព្ទដ៏ពីពេះរបស់អញ លាឮខ្ចរខ្ចាយទៅ យ៉ាងនេះថា មហាគោវិន្ទព្រាហ្មណ៍

ព្រហ្មានំ បស្សតិ សក្កិ បហោតោវិន្ទោ ព្រាហ្មណោ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ មន្តេតីតិ ន ខោ បនាហំ តោតិ ព្រហ្មានំ បស្សាមិ ន ព្រហ្មុនា សាកច្ឆេមិ ន ព្រហ្មុនា សល្លបេមិ ន ព្រហ្មុនា មន្តេមិ សុតំ ខោ បន មេតំ ព្រាហ្មណានំ វុឌ្ឍានំ មហាសាលានំ អាចរិយបាចរិយានំ ភាសមានានំ យោ វស្សិតេ ចតុត្ថេ មាសេ បដិសល្លីយតិ តស្សុណំ ឈានំ ឈាយតិ សោ ព្រហ្មានំ បស្សតិ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ មន្តេតីតិ ឥច្ឆាមហំ តោតិ វស្សិតេ ចតុត្ថេ មាសេ បដិសល្លីយិតុំ តស្សុណំ ឈានំ ឈាយិតុំ នម្ហិ តេនចិ ឧបសង្កមិតព្ពោ អញ្ញត្រ ឯតេន តុត្តាហារេន ។ យស្សុទានិ ភវំ តោវិន្ទោ តាលំ បញ្ញតីតិ ។ អថខោ តោ បហោតោវិន្ទោ ព្រាហ្មណោ បុរត្ថិមេន នគរស្សុ ទ្វារំ សណ្ឋាគារំ តារាបេត្វា វស្សិតេ ចតុត្ថេ មាសេ បដិសល្លីយិ តស្សុណំ ឈានំ ឈាយិ ។ តាសុ[1] តោចិ ឧបសង្កមតិ[2] អញ្ញត្រ

---

១ ម. តាសុ ។ ម. តាសុធ ។ ២ ម. ឧបសង្កមិ ។

អាចឃើញព្រហ្មដោយផ្ទាល់ខ្លួន មហាគោវិន្ទព្រាហ្មណ៍ អាចសាកសួរ
និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្ម ដោយផ្ទាល់ខ្លួនបាន នែនាង៎ដ៏
ចំរើន តែខ្លួនអញ មិនបានឃើញព្រហ្មសោះ មិនបានសាកសួរ ជា
មួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លង ជាមួយនឹងព្រហ្ម មិនបានប្រឹក្សា
ជាមួយនឹងព្រហ្មទេ ខ្លួនអញ គ្រាន់តែឮសេចក្តីដំណាលនេះ របស់
ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យ
និយាយថា បុគ្គលណា សមំនៅក្នុងវដ្តវៀងអស់ ៤ ខែ ពិចារណាទូវតុ-
ណាឈាន បុគ្គលនោះ នឹងឃើញទូវព្រហ្ម នឹងសាកសួរ និយាយឆ្លើយ
ឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន នែនាង៎ដ៏ចំរើន ឥឡូវអញក្រាបថា ដើម្បី
សមំនៅក្នុងវដ្តវៀងអស់ ៤ ខែ ដើម្បីនឹងពិចារណា ទូវតុណាឈាន
មិនត្រូវឲ្យអ្នកណាមួយ ចូលទៅរកអញឡើយ រៀវលែងតែបុគ្គលម្នាក់
ជាអ្នកនាំអាហារទៅឲ្យ ។ ប្រពន្ធទាំង ៤០ នាក់ ទទួលតបថា គោវិន្ទ-
ព្រាហ្មណ៍ដ៏ចំរើន សំគាល់ទូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នក
ដ៏ចំរើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ឲ្យសាង៎អាស្រមថ្មី នាទិស
ខាង៎កើតព្រះនគរ ហើយសមំនៅក្នុងវដ្តវៀងអស់ ៤ ខែ ពិចារណា
ទូវតុណាឈាន ។ មិនមានអ្នកណាចូលទៅរកគាត់ឡើយ រៀវលែងតែ

ឯតេសុ ភគ្គវាហរេដាតិ(១) ។ អថខោ តេ មហាសោ-
ណ្ឌសិរ្ហព្រាហ្មណាសិរ្ហ ចតុន្នំ មាសានំ អច្ចយេន អហុទេវ
ទុក្កណ្ឌាតា អហុ បរិតស្សតា សុតំ ខោ បនេតំ
ព្រាហ្មណានំ វុឌ្ឍានំ មហាសុតានំ អាចរិយបាចរិយានំ
អាសមានានំ យោ វាសិដ្ឋេ ចង្កមេ មានសេ បដិ-
សល្លីយតិ តស្មិំ ឈានំ ឈាយតីតិ សោ ព្រហ្មានំ
បស្សតិ ព្រហ្មានា សាតន្តេតិ សល្លបតិ មន្តេតីតិ ន ខោ
បនាហំ ព្រហ្មានំ បស្សាមិ ន ព្រហ្មានា សាតន្តេមិ
ន ព្រហ្មានា សល្លបេមិ ន ព្រហ្មានា មន្តេមីតិ ។ អថ-
ខោ តេ ព្រហ្មា សនង្កុមារោ មហាសោណ្ឌសិរ្ហព្រាហ្ម-
ណាសិរ្ហ ឥតិសោ ឥតោបរិតស្តេបញ្ញាយ សេយ្យថាបិ

---

១ ម. ភគ្គវាហរេដ ។

បុគ្គលម្នាក់ ជាអ្នកនាំអាហារទៅឲ្យ ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង កាលកន្លង៧ ៤ ខែហើយ មហាគោវិន្ទព្រាហ្មណ៍ កើតសេចក្តីអផ្សុក អន្ទះអន្ទែងថា អាគ្មាអញ ផ្ទាប់ព្ងុសេចក្តីដំណាលនេះ របស់ពួកព្រាហ្មណ៍ ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យ និយាយថា បុគ្គលណា សម្ងំនៅកន្លងរដូវក្តៀងអស់ ៤ ខែ ពិចារណា នូវកុណាឈាន បុគ្គលនោះ នឹងឃើញព្រហ្ម នឹងសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន តែ(ឥឡូវនេះ) អាគ្មាអញ មិនបានឃើញព្រហ្មសោះ មិនបានសាកសួរ ជាមួយនឹងព្រហ្ម មិនបាននិយាយ ឆ្លើយឆ្លង ជាមួយនឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្ម ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង សនង្កុមារព្រហ្ម បានដឹងច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្ត របស់មហាគោវិន្ទព្រាហ្មណ៍ ដោយចិត្តរបស់ខ្លួនហើយ ក៏ស្រាប់តែបាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះមុខ មហាគោវិន្ទព្រាហ្មណ៍ ប្រៀបដូចជា

ជាម ពលវា បុរិសោ សម្ចិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្ចិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ មហាគោវិន្ទស្ស ព្រាហ្មណស្ស សម្មុខេ បាតុរហោសិ ។ អថខោ គោ មហាគោវិន្ទស្ស ព្រាហ្មណស្ស អហុទេវ ភយំ អហុ ឆម្ភិតត្តំ អហុ លោមហំសោ យថាតំ អនិដ្ឋបុព្វំ រូបំ ទិស្វា ។ អថខោ គោ មហាគោវិន្ទោ ព្រាហ្មណោ ភីតោ សំវិគ្គោ លោមហដ្ឋជាតោ ព្រហ្មានំ សនង្កុមារំ តាថាយ អជ្ឈភាសិ

(៦៣) វណ្ណវា យសវា សិរីមា
គោ នុ ភូមសិ មារិស
អជានន្តា តំ បុច្ឆាម
កថំ ជានេមុ តំ មយន្តិ(១) ។
មំ វេ កុមារំ ជានន្តិ
ព្រហ្មលោកេ សនន្តនំ(២)

---

១ ង. មយំ ។ ២ ម. សនន្តនោ ។

បុរសមានកំឡាំងលាដៃ ដែលខ្ជួនបត់ចូល ឬបត់ដៃដែលខ្ជួនលាចេញ ។ ម្នាលអ្នកដ៏ចំរើន លំដាប់នោះឯង សេចក្តីភ័យ សេចក្តីតក់ស្លុត នឹងការព្រឺពេម ក៏កើតឡើងដល់មហាគោវិន្ទព្រាហ្មណ៍ ព្រោះបានឃើញរូបដែលខ្លួនមិនធ្លាប់ឃើញសោះ ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ និយាយទៅនឹងសនង្កុមារព្រហ្ម ទាំងកំតភ័យ តក់ស្លុត ព្រឺពេម ដោយគាថា ថា

(៦៣) បពិត្រលោកនិព្ពុត លោកជាអ្វីហ្ន៎ ទើបមានសម្បុរមានយស មានសិរី (យ៉ាងនេះ) យើងមិនស្គាល់ ឬបានជាសូមសួរលោក ឆ្លើយដូចម្តេចហ្ន៎ យើងនឹងស្គាល់លោក ។

សនង្កុមារព្រហ្មឆ្លើយថា ពួកជនតែង ស្គាល់ខ្ញុំថា ជាកុមារ ក្នុងព្រហ្មលោក មកអស់កាលយូរហើយ

សព្ពេ ជានន្តិ មំ នេកា
ឃាំ តោវិន្ទ ជានហិ(១) ។
អាសនំ ឧទកំ បជ្ជំ
មធុបាកញ្ច(២) ព្រហ្មុនោ
អគ្ឃេ ភរន្តិ បុច្ឆាម
អគ្ឃំ ក្ករុត្តុ នោ ភវំ ។
បដិក្ខណ្ហាម តេ អគ្ឃំ
យំ ភូំ តោវិន្ទ ភាសសិ
និដ្ឋេ ធម្មេ ហិតត្ថាយ(៣)
សម្បរាយសុខាយ ច
កតាវកាសោ បុច្ឆស្សុ
យញ្ញិច្ឆសិ អភិបត្ថិតន្តិ ។

(៦៤) អថខោ តោ មហាតោវិន្ទស្ស ព្រាហ្មណស្ស ឯតទហោសិ កតាវកាសោ ខោម្ហិ ព្រហ្មុនា សនង្កុមារេន តេន្ទ្ហ ខោ អហំ ព្រហ្មុនំ សនង្កុមារំ បុច្ឆេយ្យំ និដ្ឋធម្មិកំ វា អត្ថំ សម្បរាយិកំ វាតិ ។ អថខោ តោ

---

១ ម. ជានាហិ ។ ២ ម. មធុសាតញ្ច ។ ៣ ឧ. ម. ទិដ្ឋធម្មហិតត្ថាយ ។

ពួកទេវតាទាំងពួងសោត កំស្គាល់ខ្ញុំដែរ ម្នាលគោវិន្ទ
អ្នកចូរដើរយ៉ាងនេះចុះ ។

មហាគោវិន្ទព្រាហ្មណ៍ និយាយថា អាសនៈទឹក
ប្រៃ សម្រាប់លាបដើរ នឹងទឹកឃ្មុំ តែងមានដល់ព្រហ្ម
យើងសូមទទួលលោកដ៏ចំរើន ដោយគ្រឿងទទួលក្បៀ សូម
លោកដ៏ចំរើន ទទួលគ្រឿងទទួលក្បៀ របស់យើងចុះ ។

សនង្កុមារព្រហ្មឆ្លើយថា ម្នាលគោវិន្ទ អ្នកពោលចំពោះ
គ្រឿងទទួលក្បៀណា យើងព្រមទទួលគ្រឿងទទួលក្បៀ
នោះ របស់អ្នក យើងបើកឧកាសឲ្យអ្នកសួរហើយ ដើម្បី
ប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងបរលោកផង
អ្នកប្រាថ្នាប្រយោជន៍ណាមួយ ចូរសួរប្រយោជន៍នោះចុះ ។

(៦៤) ម្នាលអ្នកដ៏ចំរើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍
មានសេចក្តីត្រិះរិះ យ៉ាងនេះថា សនង្កុមារព្រហ្ម ឃានបើកឧកាសដល់អញ
ហើយ អាត្មាអញ គួរសួរអ្វីនឹងសនង្កុមារព្រហ្មហ្ន៎ គួរសួរប្រយោជន៍
កងបច្ចុប្បន្ន ឬប្រយោជន៍ក្នុងបរលោក ។ ម្នាលអ្នកដ៏ចំរើន គ្រានោះ

បមាគោវិន្ទស្ស ព្រាហ្មណស្ស ឯតទហោសិ កុសលោ
ខោ អហំ ឥដ្ឋធម្មិកានំ អត្ថានំ អញ្ញេបិ មំ ឥដ្ឋធម្មិកំ
អត្ថំ បុច្ឆន្តិ យន្នូនាហំ ព្រហ្មានំ សនង្កុមារំ សម្បរា-
យិកញ្ហេ(១) អត្ថំ បុច្ឆេយ្យន្តិ ។ អថខោ គោ មហា-
គោវិន្ទោ ព្រាហ្មណោ ព្រហ្មានំ សនង្កុមារំ គាថាយ
អជ្ឈភាសិ

(៦៥) បុច្ឆាមិ ព្រហ្មានំ សនង្កុមារំ
កង្ខី អកង្ខី បវិវេធិយេសុ
កតដ្ឋតោ កិមិហ ច(២) សិក្ខមានោ
បបេ្បតិ មច្ចោ អមតំ ព្រហ្មលោកំ ។
ហិត្វា មមត្តំ មនុជេសុ ព្រហ្មេ
ឱកោធិកោ កេ កុណាធិមុត្តោ(៣)
ឯកាមតោ វិវតោ មេថុនស្មា
ឯតដ្ឋតោ ឯត្ថ ច សិក្ខមានោ
បបេ្បតិ មច្ចោ អមតំ ព្រហ្មលោកំ ។

---

១ សម្បរាយិកំយេវ ។ ២ ម ឋិ ។ ៣ ម. ករុណោធិមុត្តោ ។

មហាគោវិន្ទព្រាហ្មណ៍ មានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញ ជាមនុស្សឈ្លាសវៃ ចំពោះប្រយោជន៍ ក្នុងបច្ចុប្បន្នស្រាប់ហើយ ទាំងពួកជនដទៃ ក៏តែងសួរកេរប្រយោជន៍ ក្នុងបច្ចុប្បន្ន នឹងអាត្មាអញដែរ បើដូច្នោះ គួរតែអាត្មាអញ សួរសនង្កុមារព្រហ្ម ចំពោះប្រយោជន៍ ក្នុងបរលោក តែមួយយ៉ាងប៉ុណ្ណោះ ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ បាននិយាយនឹងសនង្កុមារព្រហ្ម ដោយគាថា ថា

(៦៥) ខ្ញុំមានសេចក្តីសង្ស័យ សូមសួរសនង្កុមារព្រហ្ម ដែលជាអ្នកមិនមានសេចក្តីសង្ស័យ ក្នុងប្រស្នាទាំងឡាយ ដែលបុគ្គលដទៃគួរដឹងថា សត្វបិតនៅក្នុងធម៌អ្វី សិក្សាក្នុងធម៌អ្វី ទើបដល់នូវព្រហ្មលោក ដែលមិនស្លាប់ ។

សនង្កុមារព្រហ្មតបថា ម្នាលព្រាហ្មណ៍ សត្វលះបង់នូវសេចក្តីប្រកាន់ថា របស់អញក្នុងពួកសត្វចេញ ជាបុគ្គលប្រព្រឹត្តតែម្នាក់ឯង មានចិត្តខ្ពស់ទៅរកកុណាឈាន ប្រាសចាកកិលេសគឺកិលេស រៀរចាកមេថុនធម្ម បិតនៅក្នុងធម៌ទាំងនេះ លុះសិក្សាក្នុងធម៌ទាំងនេះហើយ ទើបដល់នូវព្រហ្មលោក ដែលមិនស្លាប់ ។

សុត្តន្តបិដកេ ទីឃនិកាយស្ស មហាវគ្គោ

[៦៦] ឥតិ ឥមស្មិំ មមត្តន្តិ អមាំ(១) កោតោ អាជានាមិ ។ ឥតេកច្ចេ អប្បំ វា កោតក្ខន្ធំ បហាយ មហន្តំ វា កោតក្ខន្ធំ បហាយ អប្បំ វា ញាតបរិវដ្តំ បហាយ មហន្តំ វា ញាតបរិវដ្តំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្ពជន្តិ ឥតិ ហិត្វា មមត្តំតំ សមាំ(២) កោតោ អាជានាមិ ។ ឱកោធកភូតោតំ សមាំ(៣) កោតោ អាជានាមិ ។ ឥតេកច្ចេ វិវិត្តំ សេនាសនំ កដតិ អរញ្ញំ រុក្ខមូលំ បព្ពតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ បដិសល្លីយតិ(៤) ឥតិ ឱ. កោធកភូតោតំ សមាំ កោតោ អាជានាមិ ។ ករុណាធម្មុត្តាតំ សមាំ កោតោ អាជានាមិ ។ ឥតេកច្ចេ

១-២ ឱ. មមត្តំតាហំ ។ មមត្តំតិបហន្តំ បន បាឋេន ភវិតព្ពំ ។ ៣ ម. ឯកោទិភូតោតំ អហំ ។ ឯកោទិភូតោតិបហន្តំ បាឋេន ភវិតព្ពំ ។ ៤ ឱ. ម. បដិសល្លីយតីតិ ន ទិស្សតិ ។

(៦៦) មហាគោវិន្ទព្រាហ្មណ៍ និយាយតបថា (ត្រង់ពាក្យ) របស់លោកដ៏ចំរើនថា លះបង់នូវសេចក្តីប្រកាន់ថា របស់អញចេញដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ លះបង់នូវគំនរទ្រព្យតិចក្តី លះបង់នូវគំនរទ្រព្យច្រើនក្តី លះបង់នូវញាតិវង្សតិចក្តី លះបង់នូវញាតិវង្សច្រើនក្តី ហើយកោរសក់នឹងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស (ត្រង់ពាក្យ) របស់លោកដ៏ចំរើនថា លះបង់នូវសេចក្តីប្រកាន់ថា របស់អញចេញដូច្នេះ ខ្ញុនខ្ញុំយល់ច្បាស់ហើយ ដោយប្រការដូច្នេះឯង ។ (ត្រង់ពាក្យ) របស់លោកដ៏ចំរើនថា ជាបុគ្គលប្រព្រឹត្តតែម្នាក់ឯង ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេនាសនៈស្ងាត់ចៀសគេចទៅនៅតាមព្រៃ ម្លប់ឈើ ភ្នំ ជ្រោះ រអាងភ្នំ ទីស្មសាន ព្រៃស្រោងទីវាល គំនរស្មៅឈើ (ត្រង់ពាក្យ) របស់លោកដ៏ចំរើនថា ជាបុគ្គលប្រព្រឹត្តតែម្នាក់ឯង ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ដោយប្រការដូច្នេះឯង ។ (ត្រង់ពាក្យ) របស់លោកដ៏ចំរើនថា មានចិត្តខ្ជនខ្ជៀវ នូវគុណឈាន ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ

ការុណាសមាគតេន ចេតសា ឯតំ ឯិសំ ជវិត្វា វិហារ-
តំ តថា ឧត្តរិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ
ឧទ្ធមធោ តិរិយំ សព្ពឯិ សព្ពត្តតាយ សព្ភាវឆ្ឌំ លោកំ
ការុណាសមាគតេន ចេតសា វិបុលេន មហគ្គតេន
អប្បមាណេន អវេរេន អព្យាបជ្ឈេន ជវិត្វា វិហារតំ ឥតិ
ការុណាឯិមុត្តោតំ សហំ ភោតោ អាជានាមិ ។ អាម-
គន្ធេ ច ខោ អហំ ភោតោ ភាសមានស្ស ន ច(១)
អាជានាមិ ។

(៦៧) តេ អាមគន្ធា មន្ធវេសុ ព្រហ្មេ
ឯតេ អវិច្ចា ឥធ ព្រូហិ ឆីរ
តេភជាវុជា(២) ភតិ បជា ការុរ្ហ(៣)
អាចាយិតា ឆីវុតព្រហ្មលោកាតិ ។

---

១ ឱ. ម. បសព្ភេ ឥរិ ។ ២ ឱ. ម. ភេតាវិជា ។ ៣ ឱ. ការុរ្ហេ ។ ម. ការុតុ ។

មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូច្នោះ ទិសទី ៣ ក៏ដូច្នោះ ទិសទី ៤ ក៏ដូច្នោះ មានចិត្តប្រកបដោយករុណា ដ៏ធំទូលាយ ដល់នូវភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោក ដែលមានសត្វតាំងអស់ ដោយយកខ្លួនឯងទៅប្រៀបនឹងសត្វតាំងពួង គ្រប់ទិស គឺ ទិសខាងលើ ទិសខាងក្រោម នឹងទិសទទឹងគឺ ទិសតូច ។ ក៏ដូច្នោះដែរ (ត្រង់ពាក្យ) របស់លោកដ៏ចំរើនថា មានចិត្តនុនទៅរកករុណាឈាន ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ដោយប្រការដូច្នេះឯង ។ តែថាខ្ញុំមិនយល់សោះនូវពាក្យ របស់លោកដ៏ចំរើន ដែលនិយាយបំពោះពួកក្ងិនពុល (នោះ) ។

(ខ្ញុំ) បពិត្រព្រហ្ម អ្វីជាពួកក្ងិនពុលក្នុងពួកសត្វ ខ្ញុំមិនស្គាល់ នូវក្ងិនពុលទាំងនុ៎ះឡើយ បពិត្រលោកជាអ្នកប្រាជ្ញ សូមលោកមេត្តាប្រាប់ឲ្យខ្ញុំបាន ក្នុងទីនេះ កាលេសដូចម្តេចដែលរួបរឹត បក់បោកពួកសត្វឲ្យមានក្ងិនអាក្រក់ នាំចូលទៅកាន់អបាយ បិទបាំងផ្លូវទៅកាន់ព្រហ្មលោក ។

តោដោ មោសវជ្ជំ ឯតតិ ច នោឡ្ភោ[1]

តនវិយតា អតិមានោ ខុស្សុយ្យោ[2]

ឥច្ចា វិចិកិច្ឆា បរហោឋ្ឋា ច[3]

លោភោ ច នោសោ ច មនោ ច មោហោ

ឯតេសុ យុត្តា អនិភមតច្ចា

អាចាយិតោ ធីវុតព្រហ្មលោតាតិ ។

(៦៨) យថា ខោ អហំ ភោតោ អាមតន្ទ

ភាសមានស្ស អាជាជាមិ តេ ច សុនិម្មនយោ អតារំ

អជ្ឈាវសតា បព្ភជិស្សាមហំ ភោ អតារម្ហា[4] អនតារិ-

យន្តិ ។ យស្សុនាធ ភវំ តោវិន្ទោ តាលំ មញ្ញតីតិ ។ អថ

ខោ ភោ មហាតោវិន្ទោ ព្រហ្មលោ យេន វេណុ ភជា

តេនុបសង្កមិ ឧបសង្កមិត្វា វេណុ ភជាំ ឯតទវោច

---

១ ឧ. ទោភោ ។ ម. ទុព្ភោ ។ ២ ឧ. ម. ខស្សុយ្យា ។ ៣ ម. បរិហោឋា ច ។ ៤ ឧ. ម. អតារស្មា ។

សនង្កុមារព្រហ្មឆ្លើយតបថា សេចក្តីក្រោធ ១ ការនិយាយកុហក ១ ការបញ្ឆោតបន្ទុំ ១ ការទ្រុស្តមិត្រ ១ សេចក្តីកំណាញ់ស្វិតស្វាញ ១ សេចក្តីមើលងាយគេ ១ សេចក្តីច្រណែន ១ សេចក្តីប្រាថ្នា ១ សេចក្តីសង្ឃឹយ ១ ការបៀតបៀនអ្នកដទៃ ១ លោភៈ ១ ទោសៈ ១ សេចក្តីស្រវឹង ១ សេចក្តីវង្វេង ១ ពួកសត្វដែលប្រកបដោយកិលេសទាំង ១៨ នេះ ឈ្មោះថាជាអ្នកមានភ្នំនពុលមិនទាន់អស់ រមែងទៅកាន់អបាយ ដែលបិទបាំងផ្លូវទៅកាន់ព្រហ្មលោក ។

(៦៨) មហាគោវិន្ទព្រាហ្មណ៍ និយាយថា ខ្ញុំយល់ច្បាស់ហើយនូវភ្នំនពុលទាំងឡាយ ដែលលោកដ៏ចំរើននិយាយ តែភ្នំនពុលទាំងនោះបុគ្គលដែលទៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ បពិត្រលោកដ៏ចំរើន ខ្ញុំនឹងចេញចាកផ្ទះទៅបួស ។ សនង្កុមារព្រហ្ម និយាយតបថា គោវិន្ទព្រាហ្មណ៍ដ៏ចំរើន សំគាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ព្រះបាទវេណុ លុះចូលទៅដល់ហើយ បានក្រាបទូលព្រះបាទវេណុយ៉ាងនេះ

อญฺเญหิ ปน อหํ ปุเรตรเมว อริยเสฏฺโฐ โลกนาโถ วฏฺฏานุสารีสตฺตานํ ฌานาภิญฺญาสมาปตฺติโย อนุปฺปาเทตฺวา อตฺตโน สพฺพญฺญุตญาณสฺเสว อาวชฺชนสมนนฺตรเมว ปวตฺตนกานิ ทสปารมิโย ปูเรตฺวา อนนฺตคุณสมฺปนฺนตาย อนนฺตญาณตาย จ ปจฺจกฺขโต ทิสฺวา ปรมตฺถปารมิโย ปูเรนฺโต ปรมตฺถุปปารมิโย ปูเรนฺโต ปรมตฺถสพฺพญฺญุตญาณสฺเสว อาวชฺชนสมนนฺตรเมว ปวตฺตนกานิ ทส

ថា ឥទ្ធ្យានេះ សូមព្រះអង្គដ៏ចំរើន សែ្វងរកបុរេហិតឯទៀត សម្រាប់នឹងប្រឹក្សាការពាដការ របស់ព្រះអង្គដ៏ចំរើនចុះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គប្រាថ្នា ដើម្បីនឹងចេញចាកផ្ទះទៅបួស ដ្បិតខ្ញុំព្រះអង្គឮព្រហ្មនិយាយអំពីកិនពុលតាំងឡាយហើយ តែកិនពុលតាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងចេញចាកផ្ទះទៅបួស ។

[៦៥] មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា ខ្ញុំព្រះអង្គសូមក្រាបទូលព្រះបាទរណៈ ជាម្ចាស់ផែនដី សូមព្រះអង្គទ្រង់ជ្រាបដោយកិច្ចពាដការចុះ ខ្ញុំព្រះអង្គលែងត្រេកអរក្នុងតំណែងបុរេហិតហើយ ។

ព្រះបាទរណៈ ត្រាស់ថា បើអ្នកខ្វះខាត ដោយវត្ថុតាំងឡាយ ដែលត្រូវការ យើងនឹងបំពេញឲ្យអ្នក បើបុគ្គលណាបៀតបៀនអ្នក យើងជាម្ចាស់ នៃសេនាលើផែនដី នឹងហាមប្រាមបុគ្គលនោះ អ្នកទុកដូចជាបិតា យើងទុកដូចជាបុត្រ ម្នាលគោវិន្ទ សូមអ្នកកុំលះបង់យើងឡើយ ។

មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា ការខ្វះខាតដោយវត្ថុតាំងឡាយ ដែលត្រូវការ មិនមានទេ

សុត្តន្តបិដកេ ទីឃនិកាយស្ស មហាវគ្គេ

ហំសិតោ(១) មេ ន វិជ្ជតិ

អមនុស្សវចោ សុត្វា

តស្មាហំ ន តហេ រមេ ។

អមនុស្សា តកថំវណ្ណោ

តត្ថេ អត្តំ អភាសថ

យញ្ហ សុត្វា ជហាសិ ឆោ(២)

តេហេ អម្ហេ ច តេវលេ ។

ឧបវុត្តស្ស មេ បុព្ពេ

យិដ្ឋកាមស្ស មេ សតោ

អត្តិ បដ្ឋលិតោ អាសិ

កុសបត្តបរិត្តតោ ។

តតោ មេ ព្រហ្មា ចាតុរហុ(៣)

ព្រហ្មលោតា សនន្តនោ

សោ មេ បញ្ហំ វិយាតាសិ

តំ សុត្វា ន តហេ រមេ ។

សន្តហាមិ អហំ តោតោ

យំ ត្វំ តោវិន្ទ អាសសិ

---

១ ម. ប. ហំសិតា ។ ២ ម. យំ សុត្វា បជហាសិ នោ ។ ៣ ម. ចាតុរតុ ។

បុគ្គលអ្នកបៀតបៀនខ្ញុំព្រះអង្គ ក៏មិនមានដែរ ប៉ុន្តែខ្ញុំព្រះអង្គ បានស្តាប់ពាក្យរបស់អមនុស្សហើយ ហេតុនោះ បានជាខ្ញុំព្រះអង្គ មិនត្រេកអរក្នុងផ្លុះទេ ។

ព្រះបាទរេណុ ទ្រង់ត្រាស់ថា អមនុស្សមានតេទ ដូចម្តេច បាននិយាយ សេចក្តីដូចម្តេចនឹងអ្នក ដែលអ្នកបានស្តាប់ហើយ នឹងលះបង់នូវផ្លុះគាំងឡាយ របស់យើងផង នូវយើងផង នូវជនគាំងអស់ផង ។

មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា កាលពីដើម ខ្ញុំព្រះអង្គ ចូលទៅពួនសម្ងំនៅតែម្នាក់ឯង កាលដែលខ្ញុំព្រះអង្គប្រាថ្នា ដើម្បីបូជាយ័ញ្ញ ខ្ញុំព្រះអង្គ ក៏ប្រមូលស្បូវនឹងស្មៅឈើ មកគរ បង្កាត់ភ្លើងឲ្យឆេះឡើង ។ លំដាប់នោះ ស្រាប់តែសនង្កុមារព្រហ្ម មកអំពីព្រហ្មលោក ប្រាកដ (នៅមុខ) ខ្ញុំព្រះអង្គ ព្រហ្មនោះ បានដោះស្រាយប្រស្នានឹងខ្ញុំព្រះអង្គ ឯខ្ញុំព្រះអង្គ ក៏បានស្តាប់នូវសេចក្តីនោះហើយ ទើបលែងត្រេកអរក្នុងផ្លុះ ។

ព្រះបាទរេណុ មានព្រះពាសនុត្តរាថា ម្នាលគោវិន្ទ អ្នកនិយាយពាក្យណា យើងក៏ដឿពាក្យនោះ

អមន្តសទ្ធាវចោ សុត្វា
កកុធំ វត្តេថ អញ្ញថា
តេ តំ អន្តរធិសទ្ធម(១)
សត្ថា គោវិន្ទ ឥតោ ភវំ ។
បណិ យថា វេឡុរិយោ
អកាសោ(២) វិមលោ សុភោ
ឯវំ សុត្វា(៣) ឥរិសទ្ធម
គោវិន្ទសទ្ធាឧសាសនេតំ ។

(៧០) សចេ ភវំ គោវិន្ទោ អគារស្មា អនគារិយំ បព្ពជិស្សតិ មយម្បិ អគារស្មា អនគារិយំ បព្ពជិស្សាម អថ យា តេ គតិ សា ឥតោ គតិ ភវិស្សតីតិ ។ អថ-ខោ តេ មហាគោវិន្ទោ ព្រាហ្មណេ យេន តេ ឆ ទិដ្ឋិយោ តេនុបសង្កមិ ឧបសង្កមិត្វា តេ ឆ ទិដ្ឋិយេ ឯតទវោច អញ្ញាធាធិ តេ(៤) ភវន្តោ បុរោហិតំ បរិយេ-សន្តុ យោ ភវន្តានំ រជ្ជេ អនុសាសិស្សតិ ឥច្ចាមហំ

---

១ អនុប្បត្តដិស្សាមតិបិ បាឋោ ។ ២ ឧ. ម. អកាចោ ។ ៣ ឧ. ម សុត្វ ។ ៤ ឧ. ម. ភោតិ នត្ថិ ។

របស់អ្នកដ៏ចំរើន អ្នកបានស្តាប់ពាក្យអមនុស្សហើយ នឹង ប្រព្រឹត្តទៅដោយឡែកដូចម្តេច យើងនោះ នឹងប្រព្រឹត្តតាម អ្នកដែរ ម្នាលគោវិន្ទ (ព្រោះថា) អ្នកដ៏ចំរើនជាគ្រូយើង ស្រាប់ហើយ ។ អ្នកប្រៀបដូចតែវាមណីនឹងតែវាពៃទូរ្យ មិនមានប្រែធារ ថ្ងាស្អាត យើងបានឮយ៉ាងនេះហើយ នឹងប្រព្រឹត្តតាមពាក្យប្រដៅរបស់អ្នកគោវិន្ទ ។

(៧០) ព្រះបាទវេណុ មានព្រះពាជនុង្ការថា ប្រសិនបើគោវិន្ទ ព្រាហ្មណ៍ដ៏ចំរើន នឹងចេញចាកផ្ទះហើយចូលទៅកាន់ផ្លូវ យើងនឹងចេញ ចាកផ្ទះទៅបួសដែរ បើគតិរបស់អ្នកយ៉ាងណា គតិរបស់យើងនឹងទៅជា យ៉ាងនោះដែរ ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ក្សត្រតាំង ៦ អង្គនោះ លុះចូលទៅដល់ហើយ បានក្រាប ទូលក្សត្រតាំង ៦ អង្គនោះ យ៉ាងនេះថា បពិត្រព្រះអង្គ ឥឡូវនេះ សូម ព្រះអង្គតាំងឡាយដ៏ចំរើន ស្វែងរកបុព្វេហិតដទៃទៀត សម្រាប់នឹង ប្រឹក្សាកិច្ចការរដ្ឋ របស់ព្រះអង្គតាំងឡាយដ៏ចំរើនចុះ បពិត្រព្រះអង្គ ខ្ញុំ

កោ អគារស្មា អនគារិយំ បព្ពជិតុំ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមានស្ស តេ ន សុនិម្មនយោ អគារំ អជ្ឈាវសតា បព្ពជិស្សាមហំ កោ អគារស្មា អនគារិយន្តិ ។ អថខោ កោ តេ ន(១) ខត្តិយោ ឯតមត្ថំ អបក្កម្ម ឯវំ សមចិន្តេសុំ ឥមេ ខោ កោ ព្រាហ្មណា(២) ជាម ឆនលុទ្ធា យន្ននូ មយំ មហាកោរិន្ទំ ព្រាហ្មណំ ឆនេន សិក្ខេយ្យាមាតិ ។ តេ មហាកោរិន្ទំ ព្រាហ្មណំ ឧបសង្កមិត្វា ឯវមាហំសុ សំវិជ្ជតិ ខោ កោ ឥមេសុ សត្តសុ រជ្ជេសុ បហូតំ សាបតេយ្យំ តតោ កោតោ យោវតកេន អត្ថោ តាវត-កំ អាហរីយតន្តិ(៣) ។ អលំ កោ មមបិទំ បហូតំ សាបតេយ្យំ ភវិស្សតិ យាវតកេន អត្ថោ តថា សាបតេយ្យំ អហំ សព្ពំ បហាយ អគារស្មា អនគារិយំ បព្ពជិស្សាមិ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមានស្ស តេ ន សុនិម្មនយោ អគារំ អជ្ឈាវសតា បព្ពជិស្សាមហំ

---

១ ឱ. កោ ន ។ ២ ឱ. ម. ខោ ព្រាហ្មណា ។ ៣ ឱ. អាហរេយ្យតន្តិ ។

ព្រះអង្គប្រាថ្នា ដើម្បីនឹងចេញចាកផ្ទះទៅបួស ដ្បិតខ្ញុំព្រះអង្គបានឮព្រហ្មនិយាយ អំពីកូនពុលទាំងឡាយហើយ កូនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងចេញចាកផ្ទះទៅបួស ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង ពួកក្សត្រទាំង ៦ អង្គនោះ ចៀសចេញទៅក្នុងទីដ៏សមគួរហើយគិតព្រមគ្នាថា ធម្មតាពួកព្រាហ្មណ៍ទាំងនេះ ជាបុគ្គលល្មោភនឹងទ្រព្យ បើដូច្នោះគួរយើងល្បួងមហាគោវិន្ទព្រាហ្មណ៍ដោយទ្រព្យ ។ ក្សត្រទាំង ៦ អង្គនោះ ក៏ចូលទៅកាមហាគោវិន្ទព្រាហ្មណ៍ ហើយថ្លែងសេចក្តីយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន សម្បត្តិកងពាជ្យទាំង៧នេះ មានច្រើន ព្រោះហេតុនោះ អ្នកដ៏ចំរើនត្រូវការដោយសម្បត្តិប៉ុន្មាន ចូរយកសម្បត្តិប៉ុណ្ណោះចុះ ។ មហាគោវិន្ទព្រាហ្មណ៍ក្រាបទូលថា កុំឡើយព្រះអង្គ សម្បត្តិរបស់ខ្ញុំព្រះអង្គនេះ បរិបូណ៌ហើយ ជាសម្បត្តិដែលព្រះអង្គដ៏ចំរើនទាំងឡាយប្រទានឲ្យ ខ្ញុំព្រះអង្គ លះចោលសម្បត្តិទាំងអស់ ហើយនឹងចេញចាកផ្ទះទៅបួស តាមពាក្យដែលខ្ញុំព្រះអង្គបានឮព្រហ្មនិយាយ អំពីកូនពុលទាំងឡាយហើយ កូនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយ នឹងលះបង់បានឡើយ

โก อสฺสาสฺส อนสฺสาสนฺติ ฯ อถ โข โก เต ฉ
ขตฺติยา ปจฺจนฺตชนปทมฺปิ สมฺปตฺเตสุ สญฺชาเต โข
โก พฺราหฺมณา ชาม สญฺชุหนฺตา ยญฺญ มยิ มหา-
ปถวินฺทฺ พฺราหฺมณา สญฺชิหิ สงฺเกยฺยามาตา เต มหา-
ปถวินฺทฺ พฺราหฺมณา อุปสงฺกมิตฺวา ฯ[1]มาหิสุ สนฺทิฏฺฐ
โข โก สมฺเปสุ สตฺตสุ ราชูสุ ปหูตา สญฺชโย
ตโต โกโต ยาวตกาหิ อตฺถา ตาวตกา อนี-
ยตาติ(๑) ฯ อถ โก มหปติ จตฺตาริสา กริยา
สาธิสิโย ตาทิหิ(๒) สพฺพา ปหาย อสฺสาสฺส
อนสฺสาสิ ปฏิสฺสุณิ ยถา โข ปน เม สุตฺ
พฺราหฺมโณ อาคตนฺทฺ โก สมานสฺส เต ฉ สุนิมฺมนยา
อสฺสาสิ อสฺสาสสตา ปฏิสฺสุณิหิ โก อสฺสาสฺส
อนสฺสาสิ ฯ สเจ กสิ โกวิโณ อสฺสาสฺส อนสฺสาสิ
ปฏิสฺสุตติ มยมฺปิ อสฺสาสฺส อนสฺสาสิ ปฏิสฺสุณิ
อถ ยา เต กตติ สา โน กตติ กริสฺสตีติ ฯ

---

๑ ฉ.ม. อาสียตนฺติ ฯ ๒ ฉ. ตาทิหิ ฯ ม. ตาทิหิ ฯ

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ នឹងចេញចាកផ្ទះទៅបួស ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង ក្សត្រតាំង ៦ អង្គនោះ ចៀសចេញទៅក្នុងទីដ៏សមគួរ ហើយគិតត្រមគ្នា យ៉ាងនេះថា ធម្មតាពួកព្រាហ្មណ៍តាំងនេះជាបុគ្គលល្មោកនឹងស្ត្រី បើដូច្នោះ គួរយើងលួងលោមមហាគោវិន្ទព្រាហ្មណ៍ ដោយពួកស្ត្រី ។ ក្សត្រតាំង ៦ អង្គនោះ ចូលទៅរកមហាគោវិន្ទព្រាហ្មណ៍ ហើយថ្លែងសេចក្តី យ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន ពួកស្ត្រីកងពស្ត្រតាំង ៧ នេះ មានច្រើន ព្រោះហេតុនោះ អ្នកដ៏ចំរើនត្រូវការដោយពួកស្ត្រីប៉ុន្មាននាក់ ចូរនាំយកពួកស្ត្រីប៉ុណ្ណោះចុះ ។ មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា កុំឡើយព្រះអង្គ អម្បាលដូចជា កញ្ញាតាំង ៤០ នាក់ របស់ខ្ញុំព្រះអង្គនេះ សុទ្ធតែមានជាតិនឹងត្រកូលស្មើគ្នា (ម្តេចក៏) ខ្ញុំព្រះអង្គ នឹងលះចោលកញ្ញាតាំងអស់នោះ ហើយចេញចាកផ្ទះទៅបួស តាមដែលខ្ញុំព្រះអង្គ បានឮព្រហ្មទិយាយ អំពីកូនពុលតាំងឡាយហើយ តែថាកូនពុលតាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះមិនងាយនឹងលះបង់បានទេ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គ នឹងចេញចាកផ្ទះទៅបួស ។ ក្សត្រតាំង ៦ អង្គ ត្រាស់ថា បើគោវិន្ទព្រាហ្មណ៍ដ៏ចំរើន នឹងចេញចាកផ្ទះទៅបួស ពួកយើងក៏ចេញចាកផ្ទះទៅបួសដែរ បើគតិរបស់អ្នក យ៉ាងណា គតិរបស់ពួកយើង ក៏យ៉ាងនោះដែរ ។

[៧១] សចេ បជាបតិ[1] កាមានំ
យត្ថ សតោ បុថុជ្ជនោ
អារម្ភោ[2] ឧទ្ធ្យា ហេហិ
ខន្តិពលសមាហិតា ។
ឯស មគ្គោ ពុជ្ឈមគ្គោ
ឯស មគ្គោ អនុត្តរោ
សន្ធម្មោ សព្ភិ រក្ខិតោ
ព្រហ្មលោកូបបត្តិយាតិ ។

[៧២] តេនហិ ភវំ មហាគោវិង្គោ[3] សត្ត វស្សានិ អាគមេតុ សត្តន្នំ វស្សានំ អច្ចយេន មយម្បិ អគារស្មា អនគារិយំ បព្ពជិស្សាម អថ យា តេ តតិ សា តេ តតិ ភវិស្សតីតិ ។ អតិថិរំ ខោ កោ សត្ត វស្សានិ ជាហំ សង្កាមិ ភវន្តេ សត្ត វស្សានិ អាគមេតុំ តោ ន្វ ខោ[4] បន កោ ជានាតិ ជីវិតានំ គមនីយោ សម្បរាយោ មត្ថាយ ភេដ្ឋព្ពំ

---

១ ម. ជហាបិ ។ ម. ជហិបិ ។ ២ ម. អារភ្ភេ ។ ម. ឯវំ ។ ៣ ម. គោវិង្គោ ។ ៤ ម. កោ ខោ ។

(៧១) មហាគោវិន្ទព្រាហ្មណ៍ ទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គតែងជាប់នៅក្នុងកាមទាំង ៥ ប្រការណា បើព្រះអង្គទាំង ៥ ប្រការ នឹងលះបង់នូវកាមទាំង ៥ ប្រការនោះចេញ សូមព្រះអង្គប្រោសប្រទូរតាមអាយាមឲ្យមាំ ប្រកបដោយកម្លាំងនៃឥទ្ធិបាទ (ផង) ។ នេះជាផ្លូវត្រង់ នេះជាផ្លូវប្រសើរ ដែលពួកសប្បុរស តែងរក្សាព្រះសទ្ធម្ម ដើម្បីទៅកើតក្នុងព្រហ្មលោក ។

(៧២) ក្សត្រទាំង ៦ អង្គ ត្រាស់ថា បើដូច្នោះ សូមមហាគោវិន្ទដ៏ចំរើន រង់ចាំអស់ ៧ ឆ្នាំ (សិន) លុះកន្លង ៧ ឆ្នាំហើយ ពួកយើងនឹងចេញចាកផ្ទះទៅបួស បើគតិរបស់អ្នក យ៉ាងណា គតិរបស់ពួកយើងក៏យ៉ាងនោះដែរ ។ មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ៧ ឆ្នាំយូរណាស់ ខ្ញុំព្រះអង្គមិនអាច នឹងរង់ចាំព្រះអង្គដល់ ៧ ឆ្នាំបានទេ បពិត្រព្រះអង្គដ៏ចំរើន នរណាឡើយនឹងអាចដឹងនូវជីវិតបាន ព្រោះបុគ្គល ត្រូវតែទៅកាន់បរលោក បុគ្គលត្រូវយល់ដោយប្រាជ្ញា

កត្តព្ពំ(១) តុ សំ ចរិតព្ពំ ព្រហ្មចរិយំ ឧត្តិ ជានស្ស អមរណំ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមតន្តេ អាសមានស្ស តេ ឧ សុនិម្មនយា អតារំ អជ្ឈាវសតា បព្ពជិស្សាមហំ តោ អតារស្មា អនតារយន្តិ ។ តេនហិ តវំ តោវិន្ទោ ឧ វស្សានិ អាគមេតុ ។ បេ ។ បញ្ច វស្សានិ អាគមេតុ ។ ចត្តារិ វស្សានិ អាគមេតុ ។ តីណិ វស្សានិ អាគមេតុ ។ ទ្វេ វស្សានិ អាគមេតុ ។ ឯកំ វស្សំ អាគមេតុ ឯកស្ស វស្សស្ស អច្ចយេន មយ្ហំ អតារស្មា អនតារយំ បព្ពជិស្សាម អថ យា តេ កតិ សា នោ កតិ ភវិស្សតីតិ ។ អតិចិរំ ខោ តោ ឯកំ វស្សំ នាមាំ សង្កាមិ តវន្តេ ឯកំ វស្សំ អាគមេតុំ តោ ឧ ខោ បន តោ ជានាតិ ជីវិតានំ តមនិយោ សម្បកាយោ មច្ចាយ តេជ្ជពុំ កត្តព្ពំ តុសលំ ចរិតព្ពំ ព្រហ្មចរិយំ ឧត្តិ ជានស្ស អមរណំ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមតន្តេ អាសមានស្ស តេ ឧ សុនិម្មនយា អតារំ អជ្ឈាវសតា

---

១ ម. ពោជ្ឈពុមកត្តព្ពំ ។ ម. ពោជ្ឈពុំ ..... ។

